H3

# សៀវភៅ

# ហ្វឹកហ្វឺនសិទ្ធិមនុស្ស

## Human Rights Training Textbook

## សំរាប់

## For

## បង្រៀនមន្ត្រីរាជការ

## Government Officials

រៀបចំដោយ

**អង្គការក្រៅរដ្ឋាភិបាលចំរុះ**

នៃក្រុមការងារអភិវឌ្ឍន៍កម្មវិធីសិក្សាសិទ្ធិមនុស្ស

# រៀបរៀងដោយ

អង្គការក្រៅរដ្ឋាភិបាលចំរុះ

**នៃ**

ក្រុមការងារអភិវឌ្ឍន៍កម្មវិធីសិក្សាសិទ្ធិមនុស្ស

**ក្រុមពិភាក្សា :**

| | | | |
|---|---|---|---|
| ១. | លោក | **ឆន សារាយ** | សមាគមអាដហុក |
| ២. | លោក | **ខៀត សាម៉ុន** | អង្គការ CHRTF (Task Force) |
| ៣. | លោក | **ម៉ី សុវណ្ណារ៉ា** | UN-COHCHR |
| ៤. | លោក | **អ៊ិន បូផា** | សាស្ត្រាចារ្យច្បាប់ |
| ៥. | លោកស្រី | **ជា មួយគ្រី** | កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន |
| ៦. | លោក | **ជុំ ផល្លី** | សមាគមអាដហុក |
| ៧. | លោក | **សឺន សែត** | សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម |
| ៨. | លោក | **ខេព ថ៉ា** | សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម |
| ៩. | លោកស្រី | **ទឹម ស៊ីសូជា** | អង្គការលីកាដូ |
| ១០. | លោក | **មាស សាវ៉ាត** | YRDP |
| ១១. | លោក | **ត្លូង វិសេស** | អង្គការវិថីខ្មែរ |
| ១២. | លោក | **ផេង ហ៊ិន** | អង្គការលីកាដូ |
| ១៣. | លោក | **នី ចរិយា** | សមាគមអាដហុក |
| ១៤. | អ្នកស្រី | **លឹម មុន្នី** | សមាគមអាដហុក |
| ១៥. | អ្នកស្រី | **ប៊ុន វីណា** | សមាគមអាដហុក |
| ១៦. | លោក | **ប្រាជ្ញ វុត្ថាលិន** | សមាគមអាដហុក |

**ក្រុមចងក្រង និងបោះពុម្ព :**

| | | | |
|---|---|---|---|
| ១. | លោក | **យី សុខសាន្ត** | សមាគមអាដហុក |
| ២. | លោក | **កែ ផុស** | សមាគមអាដហុក |
| ៣. | កញ្ញា | **ឆន សុគន្ធា** | សមាគមអាដហុក |

# មាតិកា

ល.រ ទំព័រ


| ល.រ | | ទំព័រ |
|---|---|---|
| | បុព្វកថា | ១ |
| | វត្ថុបំណង | ២ |
| | វិធីសាស្ត្រក្នុងការហ្វឹកហ្វឺន | ២ |
| | **សិទ្ធិមនុស្ស** | ៣ |
| ១. | និយមន័យ | ៣ |
| ២. | សិទ្ធិជាមូលដ្ឋាន | ៣ |
| ៣. | សិទ្ធិអប្បភាគជន ( ជនភាគតិច ) | ៦ |
| ៤. | សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ | ៧ |
| ៥. | សិទ្ធិពលរដ្ឋ និងនយោបាយ | ១៥ |
| ៦. | សិទ្ធិកាតព្វកិច្ច និងការទទួលខុសត្រូវ | ១៨ |
| | **សិទ្ធិស្ត្រី** | ២៥ |
| ១. | និយមន័យ | ២៥ |
| ២. | សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស | ២៦ |
| ៣. | តុល្យភាពផ្នែកភេទ | ២៩ |
| ៤. | ការរើសអើងនឹងស្ត្រី | ៣០ |
| ៥. | សិទ្ធិកុមារ | ៣៣ |
| ៦. | ការពង្រត់ ជួញដូរ និងការធ្វើអាជីវកម្មលើមនុស្ស | ៣៥ |
| ៧. | អំពើហិង្សាក្នុងគ្រួសារ | ៤០ |
| | **លទ្ធិប្រជាធិបតេយ្យ** | ៤៧ |
| ១. | ស្ថាប័ននៃរបបប្រជាធិបតេយ្យ | ៤៨ |
| ២. | នីតិវិធីនៃលទ្ធិប្រជាធិបតេយ្យ | ៤៩ |
| ៣. | តម្លៃនៃលទ្ធិប្រជាធិបតេយ្យ | ៥០ |
| | **វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា** | ៥២ |
| ១. | និយមន័យ | ៥២ |
| ២. | តួនាទី និងមុខងារឃុំ-សង្កាត់ | ៥៣ |
| ៣. | សារៈប្រយោជន៍នៃវិមជ្ឈការ | ៥៤ |
| | **នីតិរដ្ឋ ឬធម្មាធិបតេយ្យ** | ៥៥ |
| ១. | នីតិរដ្ឋ/ធម្មាធិបតេយ្យ | ៥៥ |
| ២. | ហេតុអ្វីចាំបាច់មាននីតិរដ្ឋ? | ៥៦ |
| ៣. | គោលការណ៍សំខាន់ៗដែលកំណត់នីតិរដ្ឋ | ៥៧ |

# បុព្វកថា

ក្នុងកិច្ចសហប្រតិបត្តិការរួមរវាងអង្គការក្រៅរដ្ឋាភិបាល *សមាគមអាដហុក លីកាដូ វិជីលែន ក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជា សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម អង្គការអភិវឌ្ឍន៍ធនធានយុវជន និងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំព្រះរាជាណាចក្រកម្ពុជា* បានបង្កើតឡើង អត្ថបទមេរៀនសិទ្ធិមនុស្ស សំរាប់បង្រៀនដល់មន្ត្រីរាជការ នគរបាល និងយោធា, កងរាជអាវុធហត្ថនៅខេត្ត-ក្រុងនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

*<u>សៀវភៅនេះនឹងដាក់បញ្ចូលមាត្រាច្បាប់នានាដែលពាក់ព័ន្ធ កាតព្វកិច្ចរដ្ឋ និងគោលការណ៍ប្រជាធិបតេយ្យ ។ ការបោះឆ្នោតឃុំ-សង្កាត់ គឺជារបស់មួយដ៏សំខាន់នៃអភិក្រមប្រជាធិបតេយ្យបនីយកម្មនៅមូលដ្ឋាន</u>* ។ សង្គមប្រជាធិបតេយ្យមិនអាចមានភាពរឹងមាំបានល្អទេ ប្រសិនបើគ្មានការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានទេនោះ ។ ការបោះឆ្នោតឃុំ-សង្កាត់មិនត្រឹមតែមានគោលដៅ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋានប៉ុណ្ណោះទេ គឺថែមទាំងជួយជំរុញឱ្យមានការរីកចំរើនខាងអភិបាលកិច្ចល្អ តាមរយៈការធ្វើវិមជ្ឈការ គឺការផ្ទេរអំណាច ពីរដ្ឋាភិបាលកណ្តាលឱ្យមករដ្ឋអំណាចមូលដ្ឋាន ។ ការធ្វើវិមជ្ឈការបានល្អនឹងមានការជះឥទ្ធិពលដ៏ល្អដល់ការធ្វើអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានផងដែរ ។ រដ្ឋអំណាចឃុំ-សង្កាត់ជាក៏រិតរដ្ឋអំណាចមួយ ដែលគ្រប់គ្រងផ្ទាល់នឹងប្រជារាស្ត្រ ជារដ្ឋអំណាចដែលដឹងសុខទុក្ខការលំបាករបស់ប្រជារាស្ត្រច្រើនជាងរដ្ឋអំណាចនានា ហើយក៏អាចមានលទ្ធភាពដោះស្រាយ ឬឆ្លើយតបទៅនឹងសំណូមពរការលំបាករបស់ប្រជារាស្ត្រ បានទាន់ពេលវេលាផងដែរ ។

សៀវភៅនេះមានបញ្ចូលសិទ្ធិសេដ្ឋកិច្ច សង្គម ដែលមន្ត្រីមូលដ្ឋាន ចាំបាច់ត្រូវតែយកចិត្តទុកដាក់ថាជាបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួននិងជាបញ្ហាសំខាន់នៅក្នុងការគ្រប់គ្រងរបស់ខ្លួន ។

# វត្ថុបំណង

ដើម្បីបង្កើនចំណេះដឹងថ្មីខ្លះៗដល់មន្ត្រីរាជការមូលដ្ឋាន ចំណេះដឹងថ្មីនេះមានដូចជា វិមជ្ឈការ តួនាទីរបស់មន្ត្រីដែលបានជាប់ឆ្នោតពីប្រជារាស្ត្រ បញ្ហាតម្លាភាព និងការចូលរួមរបស់ប្រជារាស្ត្រ នៅក្នុងការគ្រប់គ្រងឃុំ-សង្កាត់ ។ល។

ដើម្បីបញ្ជាក់ឱ្យបានកាន់តែច្បាស់លាស់ថែមទៀត ដល់មន្ត្រីមូលដ្ឋានអោយយល់បានត្រឹមត្រូវនៅក្នុងភារកិច្ចរបស់ខ្លួនក្នុងការគោរព ការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។ ពិសេស គឺចង់ឱ្យមន្ត្រីឃុំ-សង្កាត់មានអាកប្បកិរិយាត្រឹមត្រូវក្នុងការគ្រប់គ្រងឃុំ-សង្កាត់របស់ខ្លួន ដោយមិនឱ្យមានការរើសអើងដល់ប្រជារាស្ត្រដែលមាននិន្នាការនយោបាយខុសពីខ្លួន ប្រជាជនភាគតិច ឬក៏ប្រជារាស្ត្រដែលកាន់សាសនាខុសពីខ្លួន ។ល។ និង ។ល។ មន្ត្រីរាជការត្រូវតែយកមតិយោបល់របស់រាស្ត្រមកពិចារណា នៅក្នុងការរៀបចំគំរោងអភិវឌ្ឍន៍ឃុំ-សង្កាត់របស់ខ្លួន ឬនៅក្នុងការសំរេចចិត្តធំៗរបស់ខ្លួន ។ មន្ត្រីរាជការត្រូវតែចាត់ទុកថា រាស្ត្រជាម្ចាស់ រីឯខ្លួនជាអ្នកបំរើផលប្រយោជន៍ជូនរាស្ត្រ ដោយមិនធ្វើខ្លួនឱ្យឃ្លាតឆ្ងាយពីរាស្ត្រនោះឡើយ ។ មន្ត្រីរាជការមិនត្រូវយកអំណាចពីរាស្ត្រទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ក្រុមបក្សពួកខ្លួនឬយកអំណាចទៅសំឡុតគំរាមកំហែងរាស្ត្រ ធ្វើបាបរាស្ត្រ រំលោភសិទ្ធិរាស្ត្រនោះឡើយ ។ ព្រោះរាស្ត្រជាម្ចាស់សន្លឹកឆ្នោតជាម្ចាស់អំណាច នឹងធ្វើការវិនិច្ឆ័យទោសកំហុស របស់មន្ត្រីរាជការនៅក្នុងការបោះឆ្នោតអាណត្តិក្រោយទៀត ។

# វិធីសាស្ត្រក្នុងការហ្វឹកហ្វឺន

ការបង្រៀននឹងធ្វើតាមរយៈវិធីសាស្ត្របែបចូលរួម ដោយការផ្តល់សុន្ទរកថាខ្លី និងទុកពេលច្រើនសំរាប់ធ្វើពិភាក្សាជារួមតាមក្រុមតូចៗ លើករណីសិក្សាផ្សេងៗគ្នា ដើរតួសម្តែងរឿងតាមក្រុម ល្បែងកំសាន្តនានា ។ល។

# សិទ្ធិមនុស្ស

**វត្ថុបំណង**

ក្រោយពីអ្នកអានបានអានចប់មេរៀននេះទៅ គេនឹងអាចវិភាគ និងបានយល់ថា :

១- សិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប ពិតជាមានភ្ជាប់មកពីកំណើត

២- សិទ្ធិមនុស្សត្រូវតែមានការទទួលស្គាល់ និងការពារលើកស្ទួយដោយរដ្ឋ

៣- សិទ្ធិមនុស្សមានលក្ខណៈសាកល និងមិនអាចចែកដាច់ពីគ្នាបានទេ

៤- អ្វីជាការរំលោភសិទ្ធិមនុស្ស

## ១. និយមន័យ

**សិទ្ធិ** គឺជា ការទាមទារអំណាច ឬ ជាការប្រគល់អំណាច នូវអ្វីគ្រប់យ៉ាង ដែលមនុស្សជឿថា គេត្រូវមាន និងគួរតែមាន ។

សិទ្ធិមនុស្សត្រូវបានគេឱ្យនិយមន័យយ៉ាងសាមញ្ញថា: ***"សិទ្ធិមនុស្សគឺជាអ្វីៗ ដែលសំខាន់ចាំបាច់សំរាប់ការរស់រានមានជីវិតប្រកបដោយតម្លៃ និងសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស"*** ។




## ២. សិទ្ធិជាមូលដ្ឋាន

សិទ្ធិជាមូលដ្ឋានរបស់មនុស្សមាន ៥ គឺ:

- សិទ្ធិពលរដ្ឋ
- សិទ្ធិនយោបាយ
- សិទ្ធិសេដ្ឋកិច្ច
- សិទ្ធិសង្គម
- សិទ្ធិវប្បធម៌

***សិទ្ធិពលរដ្ឋ :*** ទាក់ទងទៅនឹងការរស់រានមានជីវិតរបស់បុគ្គល ។ ដូចជាគ្មានជនណាម្នាក់ ត្រូវទទួលរងការធ្វើទារុណកម្ម ប្រព្រឹត្តកម្ម ឬផ្តន្ទាទោស ដោយឃោរឃៅអមនុស្សធម៌ ឬទទួលរងនូវការបន្ទាបបន្ថោក នាំអោយបាត់បង់តម្លៃមនុស្សឡើយ ។ គ្មានជនណាម្នាក់ត្រូវគេបង្ខាំងទុកធ្វើជាខ្ញុំកញ្ជះ ឬតម្រូវអោយធ្វើការ ឬត្រូវធ្វើការជាចាំបាច់ឡើយ ។ សិទ្ធិមានសេរីភាពខាងបញ្ចេញមតិ សិទ្ធិមានសេរីភាពក្នុងការប្រជុំដោយសន្តិវិធី និងសិទ្ធិធ្វើបាតុកម្ម ដោយសន្តិវិធី និងសិទ្ធិមានសមភាពនៅចំពោះមុខច្បាប់ ។ល។

***សិទ្ធិនយោបាយ :*** ទាក់ទងទៅនិងការចូលរួមចំណែកក្នុងរដ្ឋាភិបាល និងសង្គម ។ ដូចជា សិទ្ធិបោះឆ្នោត តាមរយៈសន្លឹកឆ្នោតសម្ងាត់ សិទ្ធិឈរឈ្មោះជាបេក្ខជន និងសិទ្ធិបង្កើតគណបក្សនយោបាយ រួមទាំងគណបក្សប្រឆាំង ។ល។

***សិទ្ធិសេដ្ឋកិច្ច :*** ទាក់ទងទៅនឹងសន្តិសុខទ្រព្យសម្បត្តិនិងសុខុមាលភាព ។ ដូចជា សិទ្ធិធ្វើការងារ គឺសិទ្ធិរបស់ជនគ្រប់រូបក្នុងការមាន ឱកាសបង្កើនជីវភាពរស់នៅរបស់ខ្លួន ដោយសារការធ្វើការងារតាមការជ្រើសរើសរបស់ខ្លួន ឬ តាមការព្រមទទួលយក ហើយរដ្ឋាភិបាលដែលគាំទ្រ ប្រព័ន្ធសេដ្ឋកិច្ចមួយ ត្រូវផ្តល់ឱកាសអោយច្រើនល្អប្រសើរ និង ផ្តល់អោយមានកម្មវិធីនានា ដូចជា កម្មវិធីហ្វឹកហ្វឺនវិជ្ជាជីវៈ ជាដើម ។ សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារដែលអាចទទួលយកបានសិទ្ធិបង្កើតសហជីពឯករាជ្យ សិទ្ធិធ្វើកូដកម្ម សិទ្ធិមានផ្ទះសម្បែងស្នាក់នៅសមរម្យ ។ល។

***សិទ្ធិសង្គម :*** ទាក់ទងទៅនឹងសិទ្ធិចូលរួមសម្ព័ន្ធនិងគ្នាជាគ្រួសារ តាមរយៈនៃការទទួលខុសត្រូវ និងការ ទទួល ស្គាល់របស់សង្គម។ ដូចជា សិទ្ធិមានគ្រួសារ សិទ្ធិរៀបអាពាហ៍ពិពាហ៍ សិទ្ធិទទួលបាននូវការថែទាំសុខភាព និងសិទ្ធិទទួលបានការអប់រំគ្រប់គ្រាន់ ។ល។

***សិទ្ធិវប្បធម៌ :*** ទាក់ទងទៅនឹងសិទ្ធិក្នុងការសម្តែងមនោសញ្ចេតនា ការប្រកាន់យកខាងផ្នែកវប្បធម៌ តាមទ្រង់ទ្រាយច្រើនបែបច្រើនយ៉ាងរបស់សង្គម ។ ដូចជា ភ្លេង របាំ សំលៀកបំពាក់ និងភាសានៃវប្បធម៌ ផ្សេងៗគ្នា ។ល។

សិទ្ធិទាំងនេះត្រូវបានបែងចែកជាពីរជំពូកធំៗដូចខាងក្រោម:

| **សិទ្ធិពលរដ្ឋ និង នយោបាយ** | **សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌** |
|---|---|
| - សិទ្ធិរស់រានមានជីវិត | - សិទ្ធិមានចំណីអាហារហូបគ្រប់គ្រាន់ |
| - សិទ្ធិគ្មានការរើសអើង | - សិទ្ធិទទួលបាននូវលក្ខខណ្ឌរស់នៅសមរម្យ |
| - សិទ្ធិមិនទទួលការចាប់ខ្លួន ឃុំខ្លួនតាមអំពើចិត្ត | - សិទ្ធិមានការគាំពារខាងសុខភាព |
| - សិទ្ធិសេរីភាពក្នុងការដើរហើរ | - សិទ្ធិមានផ្ទះសម្បែង និងកម្មសិទ្ធិដីធ្លី |
| - សិទ្ធិមិនទទួលរងការធ្វើទារុណកម្ម | - សិទ្ធិទទួលបានការអប់រំ |
| - សិទ្ធិមានការប្រជុំដោយសន្តិវិធី | - សិទ្ធិមានការងារធ្វើ |
| - សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ | - សិទ្ធិមានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា |
| - សិទ្ធិបង្កើតគណបក្សនយោបាយ | - សិទ្ធិមិនរងការបង្ខិតបង្ខំឱ្យធ្វើការហួសកំលាំង |
| - សិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជន | - សិទ្ធិបង្កើតសហជីព |
| - សេរីភាពក្នុងការតាំងទីលំនៅ | - សិទ្ធិសំរាកលំហែវិស្សមកាល ឬមាតុភាព |
| - សិទ្ធិមានកម្មសិទ្ធិ | - សិទ្ធិសម្តែងសិល្បៈវប្បធម៌ |

ការដាក់ជាជំពូកធំទាំងពីរខាងលើនេះពុំមានន័យថា មានការបែងចែកដាច់ដោយឡែកពីគ្នានៃសិទ្ធិមនុស្សទេ ព្រោះថាជំពូកទាំងនេះមានការទាក់ទងគ្នាទៅវិញទៅមក ។ សិទ្ធិទាំងអស់នេះ មានការទាក់ទងនឹងចលនាកំរើករបស់មនុស្ស ។

## ២.ក. ភាពមិនអាចកាត់ដាច់ចេញពីគ្នានៃសិទ្ធិមនុស្ស

សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌មានភាពមិនអាចកាត់ដាច់ពីគ្នាបានទេ។ សិទ្ធិពលរដ្ឋ និងនយោបាយអាចមានន័យតិច ឬអាចមិនមានន័យ ប្រសិនបើមិនមានធនធានសេដ្ឋកិច្ច ដើម្បីជ្រោមជ្រែងសិទ្ធិទាំងនេះ ហើយដូចគ្នានេះដែរ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬការមានទ្រព្យសម្បត្តិនឹងអាចរលាយទៅវិញ កាលបើគ្មានការគោរពនិងការពារសិទ្ធិពលរដ្ឋនិងនយោបាយ ។ ដូចនេះ សិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌មានស្ថិរភាព គឺទាមទារឱ្យមានការគោរព ការការពារនូវសិទ្ធិពលរដ្ឋ និងនយោបាយរបស់ប្រជាពលរដ្ឋផងដែរ ។ ប៉ុន្តែពុំមែនមានន័យថាសិទ្ធិ ពលរដ្ឋ និងនយោបាយមានភាពប្រសើរជាងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នោះទេ ពោលគឺជំពូកសិទ្ធិមនុស្សធំៗទាំងពីរនេះ មានការអាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាចាំបាច់ ។

**សិទ្ធិពលរដ្ឋ និង នយោបាយ** ↔ **សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌**

### ២.៩. សាកលភាពនៃសិទ្ធិមនុស្ស

សិទ្ធិមនុស្សមានលក្ខណៈជាសាកល ពីព្រោះថាពូជពង្សមនុស្សកើតមកជាមួយនូវរូបកាយជា មនុស្ស និងនាំមកនូវការទាមទារជាទូទៅដូចៗគ្នា ។

ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈ វណ្ណៈ ពូជសាសន៍ ឬដើម កំណើតជាតិ ដែលមនុស្សបានកើតមកដោយមិនមានសេចក្តីប្រាថ្នាជាមុន ឬមិនបានដឹងជាមុន មិនអាច យកសំអាងបង្ហាញពីភាពខុសប្លែកគ្នាអំពីសកលភាពនៃសិទ្ធិមនុស្សបានទេ ។



ឧទាហរណ៍ៈ ប្រសិនបើអ្នក យកបារីដុតលើរាងកាយ ខ្លួនឯង រួចហើយបន្តដុតទៅលើមនុស្សដទៃពីម្នាក់ទៅម្នាក់ទៀត ដែលមាន ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ឋានៈ វណ្ណៈ ពូជសាសន៍ ឬដើមកំណើតជាតិ ខុសពីខ្លួនឯង ។ ចម្លើយដែលអ្នករំពឹង នឹងបានមកការឈឺចាប់ដូចៗគ្នា ។

### ៣. សិទ្ធិអប្បភាគជន (ជនភាគតិច)

ការសំគាល់ថា អប្បភាគជនគឺជាជនដែលមានលក្ខណៈពិសេសបីយ៉ាងគឺ មានស្ថិរភាពខាង _ជាតិពន្ធ_ _សាសនា_ និង_ភាសា_ ។ យើងអាចបង្ហាញបានខ្លះៗនូវអប្បភាគជននៅប្រទេសកម្ពុជា មានដូចជា ចិន ចាម វៀតណាម ដែលមានជាប់ជាតិពន្ធភាព ភាពខុសគ្នាខាងវប្បធម៌ ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី របៀបរស់នៅ និងភាសារបស់ពួកគេ ។

រដ្ឋាភិបាលមានកាតព្វកិច្ចធានាសិទ្ធិរបស់អប្បភាគជនដូចជា :

- សិទ្ធិមិនទទួលរងការរើសអើង សិទ្ធិមានភាពស្មើគ្នាចំពោះមុខច្បាប់

- សិទ្ធិប្រកាន់យកនូវវប្បធម៌ ភាសា សាសនា ទំនៀមទម្លាប់ និងប្រពៃណីរបស់គេផ្ទាល់ និង ដោយចំហ ។
- សិទ្ធិរៀនសូត្រភាសា ប្រវត្តិសាស្ត្រ ប្រពៃណី និងវប្បធម៌របស់ពួកគេ
- សិទ្ធិចូលរួមក្នុងជីវភាពសង្គម និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស សិទ្ធិចូលរួមក្នុងការធ្វើសេចក្ដីសម្រេច ទាំងនៅថ្នាក់ជាតិ និង ថ្នាក់តំបន់ ។
- សិទ្ធិបង្កើតនិងរក្សាសមាគម និងអង្គការនានារបស់គេផ្ទាល់
- សិទ្ធិទាក់ទងដោយសេរីនិងសន្តិវិធី ជាមួយសមាជិកក្នុងក្រុមរបស់ពួកគេ ។

## ៤. សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងសន្ធិសញ្ញាពាក់ព័ន្ធផ្សេងៗទៀត បានបញ្ញត្តិនូវកិច្ចធានារ៉ាប់រងមួយចំនួនពីរដ្ឋ ដែលទាក់ទងទៅនឹងការធ្វើអោយប្រសើរឡើងនូវសិទ្ធិទាំងនេះ ។

រដ្ឋាភិបាលជាស្ថាប័នបំរើប្រជាពលរដ្ឋ ហើយមានកាតព្វកិច្ច អនុវត្តច្បាប់ ការចាត់ចែងគ្រប់គ្រង ថែរក្សាសន្តិសុខ និងអភិវឌ្ឍន៍ប្រទេសជាតិ ។

រដ្ឋាភិបាលត្រូវគិតដល់ *ការគោរពសិទ្ធិ ការការពារសិទ្ធិ និងបំពេញសេចក្ដីត្រូវការនៃសិទ្ធិមនុស្ស* ។

### ក.សិទ្ធិទទួលការអប់រំ



ការអប់រំគឺជាដំណើរនៃការ អភិវឌ្ឍន៍គំនិតប្រាជ្ញា ចំណេះដឹង និងភាពប៉ិនប្រសប់របស់មនុស្ស ដែលបានមកតាមរយៈការរៀន និងបង្រៀន នៅឯសាលារៀន វិទ្យាល័យ និងមហាវិទ្យាល័យ ។ មនុស្សគ្រប់ៗរូបមានសិទ្ធិទទួលការអប់រំដោយ គ្មានការរើសអើងរវាង ភេទប្រុសឬស្រី វ័យក្មេងឬចាស់ ជនពិការ អ្នកក្រ អ្នកមាន ប្រភពកំណើត ពណ៌សម្បុរ ភាសា គ្រួសារអ្នកមានជម្ងឺអេដស៍ ជំនឿ សាសនា និន្នាការនយោបាយ ពូជសាសន៍អ្វីឡើយ ។ *ការរៀនសូត្រ គឺជាការជួយខ្លួនឯង !*

រដ្ឋាភិបាលមានកាតព្វកិច្ចគាំទ្រ លើកស្ទួយ និងបំពេញសិទ្ធិនេះដល់ប្រជាពលរដ្ឋដោយខានមិនបាន ។ គ្មានការរើសអើងភេទប្រុស-ស្រី វ័យក្មេង-ចាស់ ជនពិការ អ្នកក្រ អ្នកមាន ប្រភពកំណើត ពណ៌សម្បុរ ភាសា ជំនឿសាសនា និន្នាការនយោបាយ ពូជសាសន៍អ្វីឡើយ ។ លើសពីនេះទៀត រដ្ឋាភិបាលត្រូវបំពេញដល់តម្រូវការខាងការអប់រំរបស់ប្រជាពលរដ្ឋ ដោយបើកចំហលើវិស័យសិក្សាអប់រំគ្រប់ទីកន្លែងនៃប្រទេស ដូចជាស្ថាបនាអាគារសិក្សា បំពាក់សំភារៈសិក្សាទំនើប បណ្តុះបណ្តាលធនធានគ្រូបង្រៀនរួមទាំងប្រាក់បៀវត្សរ៍សមរម្យ ធ្វើយុទ្ធនាការលើកទឹកចិត្តដល់មាតាបិតាដើម្បីនាំកូនចូលមកសិក្សា និងផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋទីទ័លក្រនូវឱកាសចូលសិក្សាដោយមិនមានការបង់ថ្លៃជាដើម ។

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៤៧** : ចែងថា " *មាតា បិតាមានកាតព្វកិច្ចអប់រំកូនចៅអោយទៅជាពលរដ្ឋល្អ* " ។

**មាត្រា ៤៨** : ចែងថា " *រដ្ឋធានារក្សាសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញា ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការរៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច កាមគុណលើកុមារ ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំអោយអន្តរាយសុខភាព និងសុខុមាលភាពរបស់កុមារ* " ។

**មាត្រា ៦៥** : រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីអោយការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។ រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបភាព ។

**មាត្រា ៦៦** : រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពទូទាំងប្រទេសដែលធានាអោយ

បាននូវគោលការណ៍សេរីភាពខាងការសិក្សាធិការ និងគោរពគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីអោយពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ស្មើៗគ្នាក្នុងការកសាងជីវិត ។

**មាត្រា ៦៧**

*"រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍តុរកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជនទៅគ្រប់ភូមិសិក្សា"* ។

**មាត្រា ៦៨ :** រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀន សាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

- ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។
- រដ្ឋជួយផ្សព្វផ្សាយនិងលើកតំកើងសាលាបាលីនិងពុទ្ធិកសិក្សា ។

## ខ. សិទ្ធិមានផ្ទះសម្បែងសមរម្យ ឬមានកម្មសិទ្ធិដីធ្លី

មនុស្សគ្រប់រូបទាំងអស់ មានសិទ្ធិមានទីលំនៅសមរម្យ និងមានដីធ្លី។ នេះមានន័យថា គ្មានជនណាម្នាក់ទទួលរងនូវការដកហូតយកផ្ទះសម្បែងឬដីធ្លីដែលជាកម្មសិទ្ធិរបស់ខ្លួនតាមអំពើចិត្តឡើយ ។ គ្មានគ្រួសារនរណាម្នាក់ត្រូវរងការបណ្តេញចេញ ដោយបង្ខិតបង្ខំ និងមិនបានទទួលសំណងជួសជុលការខូចខាត ឬផ្ទុះសមស្របតាមការសុខចិត្តជាមុនឡើយ ។ *ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែជាប្រយោជន៍សាធារណៈតំរូវអោយធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងមុនដោយសមរម្យ និងយុត្តិធម៌* ។

*តើសមរម្យ និងយុត្តិធម៌ មានន័យដូចម្តេច ?*

**សមរម្យ :** គឺយកគោលការណ៍សមភាពតម្លៃដោះដូរជាមូលដ្ឋាន ។

**យុត្តិធម៌ :** គឺយកគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ជាមូលដ្ឋាន ។

ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋក៏មានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះខ្លួនឯង និងគ្រួសារផងដែរ ក្នុងការគ្រប់គ្រងដីធ្លីនិងផ្ទះសម្បែងរបស់ខ្លួន ដូចជាការប្រឹងប្រែងដាំដុះលើដីធ្លីដែលមាន ដោយមិនទុកឱ្យនៅទំនេរ និងចងក្រងសហគមន៍ ដើម្បីជួយគ្នាទៅវិញទៅមក ដើម្បីធ្វើការអំពាវនាវ ឬប្តឹងបរិហារ ឬតវ៉ាប្រឆាំងនឹងអាជ្ញាធរមូលដ្ឋានដែលរំលោភសិទ្ធិមនុស្ស ។

មនុស្សគ្រប់រូបទាំងអស់ មានសិទ្ធិមានទីលំនៅសមរម្យ និងមានដីធ្លី។ នេះមានន័យថា គ្មានជនណាម្នាក់ទទួលរងនូវការដកហូតយកផ្ទះសម្បែងឬដីធ្លីដែលជាកម្មសិទ្ធិរបស់ខ្លួនតាមអំពើចិត្តឡើយ ។ គ្មានគ្រួសារណាម្នាក់ត្រូវរងការបណ្តេញចេញ ដោយបង្ខិតបង្ខំដោយមិនបានទទួលសំណងជួសជុលការខូចខាត ឬផ្ទុរសមស្របតាមការសុខចិត្តជាមុន ។

ភាពក្រីក្រដែលមិនមានវិធានការច្បាស់លាស់ដើម្បីដោះស្រាយ បានធ្វើឱ្យប្រជា[illegible]ចិត្តលកដីធ្លី ឬផ្ទះសម្បែង ដោះដូរជាចំណីអាហារ និងថ្នាំសង្កូវដើម្បីជីវិត ។ តាមលទ្ធផលអង្កេត ធ្វើឡើងដោយអុកស្វាមជីប៊ី (**Oxfam-GB**) នៅឆ្នាំ២០០១ បានឱ្យដឹងថា ប្រជាកសិករខ្មែរប្រមាណ៣០%បានក្លាយទៅជាអ្នកគ្មានដីដាំដុះក្រោយពេលដែលលក់ដីរួច ។ ***រដ្ឋាភិបាលមានកាតព្វកិច្ច*** បែងចែកដីធ្លីសំរាប់អ្នកដែលគ្មានដីធ្លីសំរាប់សង់ផ្ទះ និងធ្វើស្រែ ឬចំការ និងត្រូវមានវិធានការការពារប្រឆាំងនឹងការរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋដោយសំណាក់អ្នកមានអំណាច និងទប់ស្កាត់ក្រុមឈ្មួញទុច្ចរិត ឬអ្នកមានអំណាចក្នុងរដ្ឋាភិបាលដែលរំលោភទិញដូរដីធ្លីមិនគិតពីផលប៉ះពាល់ដ៏អាក្រក់ដែលនឹងកើតមានចំពោះ វាសនាអនាគតរបស់ប្រជាពលរដ្ឋ ។

សិទ្ធិមានកម្មសិទ្ធិដីធ្លី គឺទទួលបាន និងធានារ៉ាប់រងដោយច្បាប់រដ្ឋ ។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ៤៤** : ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិដីធ្លី ។ កម្មសិទ្ធិស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។ ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាន លុះត្រាតែប្រយោជន៍សាធារណៈតំរូវអោយធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុកហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**អនុសញ្ញា ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌**

**មាត្រា ១១** : " *ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការមានកំរិតជីវភាពសមស្របសំរាប់ខ្លួនឯង និងគ្រួសាររាប់បញ្ចូលទាំងសិទ្ធិមានចំណីអាហារ សិទ្ធិមានសំលៀកបំពាក់ ជំរកគ្រប់គ្រាន់ និងមានសិទ្ធិទទួលបានការកែលំអរវៀងរហូតនូវលក្ខណៈរស់នៅ* " ។

**មាត្រា ៤៦** : " *រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈអោយនារី ជាពិសេសនារីនៅតាមជនបទ ដែលគ្មានទីពឹងអោយបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរមានលទ្ធភាពព្យាបាលជំងឺ អោយកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ* " ។

## ច្បាប់ភូមិបាល ឆ្នាំ២០០១

**មាត្រា ៥ :** គ្មានបុគ្គលណាមួយ ត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្ដល់សំណងជាមុនដោយ សមរម្យ និងយុត្តិធម៌ ។

### អំពីលន្ធកម្មនៃកម្មសិទ្ធិ

### ជំពូកទី៤

### អំពីការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុតាមលន្ធកម្មពិសេសនៃភោគៈ

**មាត្រា ៣០ :** បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំយ៉ាងតិច មកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។

ក្នុងករណីមានការជំទាស់ដល់ការផ្ដល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្ដុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុ ដែលមានទំនាស់ ឬយកភស្ដុតាង ដែលថាខ្លួនបានទិញអចលនវត្ថុនោះ ពីភោគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន ។

**មាត្រា ៣១ :** បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយ ក្នុងការក្លាយទៅជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួន រហូតគ្រប់រយៈពេលស្របច្បាប់រយៈពេលស្របច្បាប់ ៥ (ប្រាំ) ឆ្នាំ និងបានប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ការអនុញ្ញាតឱ្យបន្តរយៈពេលមិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធី និងមិនទាន់មានការជំទាស់ ។

អាជ្ញាធរមានសមត្ថកិច្ចដែលបដិសេធ ដោយរំលោភនូវការអនុញ្ញាតឱ្យបន្តរយៈពេលត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។

ការទទួលស្គាល់ដោយរំលោភដោយអាជ្ញាធរមានសមត្ថកិច្ច នូវភោគៈដែលមិនបំពេញលក្ខខណ្ឌនៃច្បាប់ ត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាព ។ អាជ្ញាធរដែលបានទទួលស្គាល់ដោយរំលោភនេះ ត្រូវ

ទទួលខុសត្រូវដោយផ្ទាល់ខ្លួនចំពោះច្បាប់ ។

**មាត្រា ៣៣** : ក្នុងករណីមានការដកហូតអចលនវត្ថុដោយហិង្សា ឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្តឹងទាមទារពីភោគីស្របច្បាប់នៃអចលនវត្ថុ ដែលត្រូវបានដកហូត ។ បណ្តឹងទាមទារនេះមានរយៈពេល៣ (បី) ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត ។

**មាត្រា ៣៥** : មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឱ្យអ្នកកាន់កាប់អចលនវត្ថុ គ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ ។

សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ ដោយសន្តិភាពមានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ ។

តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គល ដែលបង្ហាញប័ណ្ណត្រឹមត្រូវ និងពេញលេញរបស់សុរិយោដីបានឡើយ ។

**មាត្រា ៣៦** : បើវិធានការបណ្តេញចេញ បង្គាប់ដោយតុលាការអាចបណ្តាលឱ្យមានភាពវឹកវរ ឬមានផលវិបាក ធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ចអាចសុំពន្យារការអនុវត្តន៍ជាបណ្តោះអាសន្នបាន ។

**មាត្រា ៣៨** : ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបានលុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយពិតប្រាកដ គឺថាភោគីទោះកាន់កាប់ដោយខ្លួនឯងក្តីឱ្យអ្នកដទៃក្តី ត្រូវកាន់កាប់ឱ្យឃើញថា ការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលដៅខ្លួនជាភោគីយ៉ាងផ្តាច់មុខ កុំឱ្យឃើញថា ការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៀតវិញ ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈ ដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ ។ ភោគៈនោះត្រូវចាត់ទុកជាមោឃៈ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា គឺថាភោគៈដែលបានមកដោយហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ ។ ក៏ប៉ុន្តែបើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកជណ្តើមនោះ ហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈ ដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះ

ទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុ ដោយដឹងឮជាសាធារណៈគឺថា ភោគីត្រូវកាន់កាប់ដោយឥតលាក់បិទបាំង អ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួន លើវត្ថុនោះនឹងបានឮឃើញមិនខាន ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានអាក់ខាន គឺថាភោគីត្រូវធ្វើនូវកិច្ចការទាំងពួងតាមធម្មតាជាប្រក្រតីក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ ។ ការអាន់ខានក្នុងរយៈពេលខ្លី ឬបោះបង់ទុកឱ្យនៅទំនេរ ដើម្បីឱ្យមានជីជាតិឡើងវិញ មិនមែនជាឧបសគ្គដល់លទ្ធកម្មសិទ្ធិនោះទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយសុចរិត គឺថា ភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជនលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ ។

**មាត្រា ៤០ :** ក្នុងការរង់ចាំរៀបចំឡើងវិញនូវប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំពោះភោគៈដែលមានកន្លងមក មុនច្បាប់នេះចូលជាធរមាន ។

ប័ណ្ណសំគាល់សិទ្ធិនេះជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាប័ណ្ណកម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះដែរ ។

ប័ណ្ណសំគាល់សិទ្ធិនេះ អាចនឹងបង្កើតបានជាប័ណ្ណស្ថាពរនៃកម្មសិទ្ធិ ដែលមានលក្ខណៈមិនអាចតវ៉ាបាន លុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតសៀវភៅគោលបញ្ជីដី ។

ក្នុងករណីមានការជំទាស់ទាមទារ ការកំណត់ថានរណាជាភោគីស្របច្បាប់នៃអចលនវត្ថុនោះត្រូវផ្អែកលើការស៊ើបអង្កេតបន្ថែមនូវរាល់ភស្តុតាងដែលពាក់ព័ន្ធទាំងអស់ ។ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ គឺជាភស្តុតាងមួយ ប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ ។

**មាត្រា ៤១ :** ត្រូវហាមឃាត់ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលមិនអាចយកធ្វើជារបស់ឯកសារបាន ឬដែលមិនបានកាន់កាប់តាមលក្ខខណ្ឌស្របច្បាប់ ។

**មាត្រា ៤២ :** បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១ នៃច្បាប់នេះ ។

**មាត្រា ៤៥ :** ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះអាចធ្វើពាក្យប្ដឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## គ.សិទ្ធិមានសុខភាព

សិទ្ធិសុខភាពគឺជាសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋទាំងអស់ ។ មានន័យថា មនុស្សគ្រប់ៗរូបត្រូវទទួលបាននូវការថែទាំសុខភាពខាងផ្លូវកាយនិងផ្លូវចិត្ត តាមរយៈសេវាសាធារណៈដែលបំរើការទូទៅ មានដូចជា មន្ទីរពេទ្យ គិលានដ្ឋាន ឱសថស្ថាន មន្ទីរសម្ភព ការផ្តល់ឱសថឬថ្នាំបង្ការ និងការអប់រំលើកតម្កើងប្រាជ្ញា និងស្មារតីដល់ប្រជាពលរដ្ឋ ។ សិទ្ធិមានសុខភាពមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិផ្សេងទៀត ។ សិទ្ធិមានសុខភាពនេះ ត្រូវបានអង្គការសុខភាពពិភពលោកឱ្យការពន្យល់ថា សុខភាពគឺជាស្ថានភាពមានសុខុមាលភាពទាំងស្រុងលើរាងកាយ គំនិតប្រាជ្ញា រួមទាំងសង្គម មិនមែនគិតសំដៅតែលើឱសថ មេរោគ ឬការមានរបួសស្នាមប៉ុណ្ណោះទេ ។

រដ្ឋាភិបាលមានកាតព្វកិច្ចធានាដល់សុខភាពប្រជារាស្ត្រ ដូចជាការយកចិត្តទុកដាក់បង្ការជំងឺ ផ្តល់ការព្យាបាលជំងឺ ផ្តល់ការអប់រំខាងសុខភាពដល់ប្រជារាស្ត្រ ធ្វើពិសោធន៍និងពិនិត្យយ៉ាងម៉ត់ចត់លើការធ្វើចរាចរឱសថ ។ ប្រជារាស្ត្រក្រីក្រត្រូវទទួលបានការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ និងការអប់រំខាងសុខភាពនិងអនាម័យ ។ មន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈនានា មិនត្រឹមតែមានអាគារប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានគ្រឿងបរិក្ខារពេទ្យ ឱសថសារវ័ន្ត និងកម្មវិធីនានាអំពីសុខភាព រួមទាំងមានបុគ្គលិកពេទ្យប្រកបដោយវិជ្ជាជីវៈ និងប្រកបដោយក្រមសីលធម៌ល្អ ។

### រដ្ឋធម្មនុញ្ញ

**មាត្រា ៤៨ :** " *រដ្ឋធានារក្សាសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញា ស្តីពីកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិតសិទ្ធិទទួលការអប់រំ រៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច កាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំអោយអន្តរាយសុខភាព និងសុខុមាលភាពរបស់កុមារ* " ។

**មាត្រា៧២ :** សុខភាពប្រជារាស្ត្រត្រូវបានធានា។ រដ្ឋត្រូវយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវទទួលបានការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ រដ្ឋរៀបចំអោយមាន គិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។



គោលការណ៍មិនមានការរើសអើង ត្រូវអនុវត្តដោយគ្រូពេទ្យទាំងអស់។ គ្រូពេទ្យទាំងអស់ត្រូវផ្តល់សេវាកម្មរបស់ខ្លួនដោយមិនគិតពីរូបភាពបុគ្គលនិងធនធានសេដ្ឋកិច្ច និងត្រូវធានាថា មនុស្សគ្រប់រូបត្រូវបានទទួលនូវព័ត៌មាន បរិក្ខារពេទ្យ និងសេវាសុខាភិបាលដោយស្មើៗគ្នា ដោយមិនគិតពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ វណ្ណៈសង្គម ឬឋានៈអ្វីឯទៀតឡើយ។

## ៥. សិទ្ធិពលរដ្ឋ និងនយោបាយ

រដ្ឋាភិបាលត្រូវប្រកាសធានាដល់កិច្ចការពារសិទ្ធិមនុស្សពីការរំលោភដែលប្រព្រឹត្តដោយជនទីបី និងធានារ៉ាប់រងថា គ្មានជនណាម្នាក់ (ទោះជាឪពុកឬម្តាយក្តី) ប្រើប្រាស់អំណាចដោយហាមឃាត់កុមារមិនឱ្យទទួលបានការសិក្សា ឬធ្វើទារុណកម្មលើបុត្រា-បុត្រីរបស់ខ្លួន ឬអ្នកដទៃឯទៀត។ កាតព្វកិច្ចបែបនេះហៅថា កាតព្វកិច្ចការពារ ហើយជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។

ការមិនអើពើរបស់រដ្ឋាភិបាលចំពោះសិទ្ធិមនុស្ស គឺជាការមិនទទួលខុសត្រូវនិង ជាការរំលោភកាតព្វកិច្ចជារដ្ឋាភិបាលមួយផងដែរ។ ឧទាហរណ៍ខ្លះៗដូចជា ការចាប់មនុស្សឃុំឃាំងតាមអំពើចិត្ត ការវាយធ្វើបាប ការរឹបអូសយកដីធ្លីតាមអំពើចិត្ត ការសំឡុតគំរាមកំហែង ការជំរិតទារលុយប្រជាពលរដ្ឋ អំពើពុករលួយ ការធ្វើសេចក្តីសំរេចចិត្តអ្វីមួយដោយមិនស្តាប់យោបល់ឬសុំយោបល់ពីប្រជាពលរដ្ឋ។ល។ ការគ្មានវិធានការ

ប្រឆាំងជនរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តពីសំណាក់អាជ្ញាធរ ដូចជាមិនដាក់វិន័យ មិននាំខ្លួនជនល្មើសទៅវិនិច្ឆ័យទោសដោយតុលាការ មិនព្យួរមុខតំណែង មិនបណ្តេញចេញពីការងារ ទាំងនេះអាចបង្ហាញឱ្យឃើញ ថា ជាអំពើគ្មានការទទួលខុសត្រូវនិងរំលោភនូវកាតព្វកិច្ចរបស់ខ្លួនចំពោះសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ។

## សេរីភាពនៃការបញ្ចេញមតិ ការចូលរួម និងការបង្កើតគណបក្សនយោបាយ

សេរីភាពជាប្រភពនៃ សិទ្ធិពលរដ្ឋនិងនយោបាយ និងជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ដែលជាសេចក្តីត្រូវការជាសំខាន់បំផុតសំរាប់បុគ្គលគ្រប់រូប ។ ព្រោះថាសេរីភាពគឺអ្វីៗដែល មនុស្សអាចធ្វើទៅបានដោយមិនទទួលរងនូវការដាក់កំហិត ការឃាយឃី ការបំភិតបំភ័យ ការបង្ខិតបង្ខំ ការជ្រៀតជ្រែក ។ល។

អ្នកអាចដឹងថាអ្នកគ្មានសេរីភាព នៅពេលដែលមនុស្សណាម្នាក់យកអ្នកទៅដាក់នៅក្នុងកន្លែងមួយឯកោតែម្នាក់ឯង ឬតម្រូវឱ្យអ្នកធ្វើអ្វីមួយដោយខានមិនបានដោយគ្មានការសួរ ឬសុំយោបល់ ឬធ្វើចលនាបង្រ្កាបឱ្យអ្នកខ្លាចរអារ តក់ស្លុត បាត់បង់ ការតស៊ូ ការនិយាយស្តី ឬតវ៉ាជាដើម ។ និយាយរួមមកចលនាទាំងឡាយដែលគេបង្កើតឡើងក្នុងបំណង អាក្រក់និងក្នុងបំណងដើម្បីបំភ័យ បង្អាក់ រារាំង រំខានឃាយឃី បង្ខិតបង្ខំ ការដាក់កំហិត ឬជ្រៀតជ្រែក គឺជាចលនាបំផ្លាញនិងរំលោភសិទ្ធិមានសេរីភាពរបស់មនុស្ស ។



សិទ្ធិនៃការបញ្ចេញមតិត្រូវតែលើកស្ទួយ និងការពារជាចាំបាច់ដោយរដ្ឋ ។ មានសិទ្ធិជាច្រើនដែលទាក់ទង ទៅនឹងសេរីភាពបញ្ចេញមតិ យោបល់ ផ្សព្វផ្សាយពត៌មាន គឺមានន័យថា គណបក្សនយោបាយទាំងអស់

មាន សិទ្ធិចូលរួមប្រើប្រាស់យ៉ាងត្រឹមត្រូវ និងស្មើគ្នាទៅលើមធ្យោបាយសារពត៌មាន (តាមទស្សនាវដ្តី ព្រឹត្តិប័ត្រ វិទ្យុ និងទូរទស្សន៍) ។ ប្រជាពលរដ្ឋ អ្នកនិពន្ធ អ្នកអត្ថាធិប្បាយមានសិទ្ធិសម្តែងមតិ និងធ្វើអន្តរាគមន៍វិចារណកថា តាមទស្សនៈរបស់ខ្លួនដោយសេរី ។

## រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៣១ :** ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំង ឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៤១ :** ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ ។

របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

## សេចក្តីប្រកាសសាកល ស្តីពីសិទ្ធិមនុស្ស

**មាត្រា ១៩ :** គ្មានជនណាម្នាក់អាចឃាត់ឃាំងអ្នកមិនអោយនិយាយស្តី បញ្ចេញយោបល់ យកពត៌មាន ឬផ្តល់ពត៌មាន ទោះបីតាមរយៈសៀវភៅ កាសែត វិទ្យុ ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗទៀតក៏ដោយ ។

**មាត្រា ២០ :** ជនណាក៏ដោយក៏មានសិទ្ធិប្រើប្រាស់សេរីភាពក្នុងការប្រជុំ និងក្នុងការបង្កើតសមាគម ឬរៀបចំធ្វើបាតុកម្មផ្សេងៗដោយសន្តិវិធី ។ គ្មានជនណាអាចមកបង្ខំអ្នកអោយចូលរួមជាមួយក្រុម ឬពួកណាដែលអ្នកមិនពេញចិត្តឡើយ ។

## ៦. សិទ្ធិ ភារកិច្ច និង ការទទួលខុសត្រូវ

**ប្រជាពលរដ្ឋ** : មនុស្សគ្រប់ៗរូបមានសិទ្ធិស្មើៗគ្នា គឺមិនរំលោភបំពានលើសិទ្ធិមានសន្តិសុខរបស់អ្នកដទៃ និងមានសិទ្ធិចូលរួមរិះគន់ ប្តឹងតវ៉ា ប្តឹងបរិហារអំពើរំលោភសិទ្ធិមនុស្ស ។

**សភាជាតិ និង ព្រឹទ្ធសភា** : ជាអង្គការប្រមូលផ្តុំអ្នកតំណាងដែលបានជាប់ឆ្នោតដោយប្រជាពលរដ្ឋបានបោះឆ្នោតអោយ ។ អ្នកតំណាងទាំងនេះជាអ្នកបំរើប្រជាពលរដ្ឋ តាមរយៈការតាក់តែងនិងអនុម័តច្បាប់នានា ដើម្បីការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋពីការរំលោភនានា ឃ្លាំមើលការប្រតិបត្តិច្បាប់ និងការបំរើរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ ។

**រដ្ឋាភិបាល** : កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋគឺផ្តល់នូវការគោរព ការពារពារ ការលើកស្ទួយ និងបំពេញ ចំពោះគោលការណ៍ទាំងឡាយនៃសិទ្ធិមនុស្ស ។ រដ្ឋត្រូវបង្កើតនយោបាយ និងកម្មវិធីដើម្បីបំពេញកាតព្វកិច្ចក្នុងករណីនៃសិទ្ធិទទួលការព្យាបាលជំងឺ មានកម្មវិធីលើកស្ទួយ បង្ការ ផ្តល់ព្យាបាលជំងឺ និងការធ្វើអោយមាននីតិសម្បទាឡើងវិញ ។

- *ការគោរព:* គឺមានន័យថា មន្ត្រីរបស់រដ្ឋាភិបាលមិនត្រូវប្រព្រឹត្តដោយខ្លួនឯងនូវ អំពើ ណាដែលយើងដឹងថា ជាអំពើរំលោភសិទ្ធិមនុស្ស រំលោភច្បាប់ ។

ឧទាហរណ៍ :

- មន្ត្រីនគរបាលត្រូវមានតួនាទីការពារប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន លោកមិនត្រូវឃាត់ខ្លួនបុគ្គលណាម្នាក់ ដោយគ្មានភស្តុតាងគ្រប់គ្រាន់ និងជាក់ស្តែងនោះទេ ។
- មន្ត្រីនគរបាលមិនត្រូវធ្វើទារុណកម្មដើម្បីយកចម្លើយ ឬដោះស្រាយរឿងព្រហ្មទណ្ឌ ដោយសំណងរដ្ឋប្បវេណី ដូចជាករណីរំលោភសេពសន្ថវៈលើស្ត្រី ។

- *ការការពារ:* មន្ត្រីត្រូវមានតួនាទីមួយគឺ ឃាត់ឃាំងដល់មនុស្សទីបី ដែលរំលោភបៀតបៀនដល់សិទ្ធិមនុស្សម្នាក់ទៀត ។ មន្ត្រីនគរបាលយុត្តិធម៌ ឬតុលាការត្រូវតែឃាត់ខ្លួន ឃុំខ្លួន ដាក់ពិន័យដាក់ទោស អោយបានត្រឹមត្រូវតាមច្បាប់ដល់ជនដែលរំលោភសិទ្ធិមនុស្ស និងរំលោភច្បាប់ ។ បើមានជនណាឃុំខ្លួនមនុស្ស ដោយរំលោភ មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រម ត្រូវតែចាត់វិធានការ និងដាក់ពិន័យ កុំអោយអ្នកនោះប្រព្រឹត្តអំពើបែបនេះតទៅទៀត ។

- ***លើកស្ទួយនិងបំពេញ:*** កាតព្វកិច្ចទីបីនេះសំខាន់ណាស់ គឺរដ្ឋាភិបាលធ្វើយ៉ាងណាអោយមានការភ្ញាក់រលឹក ចូលរួមអំពីការគោរពសិទ្ធិមនុស្ស និងការអនុវត្តច្បាប់ ពីសំណាក់ប្រជាពលរដ្ឋ និងមន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់ ។ មន្ត្រីយុត្តិធម៌ត្រូវធ្វើយ៉ាងណា អោយប្រជាពលរដ្ឋមានជំនឿទុកចិត្ត មានភាពកក់ក្តៅ ក៏ដូចជាការយល់ដឹងអំពីច្បាប់ អំពីតួនាទីជាពលរដ្ឋក្នុងការចូលរួមការពារ លើកស្ទួយសិទ្ធិមនុស្ស និងការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

**តុលាការ :** តុលាការគឺជាស្ថាប័នឯករាជ្យមួយដែលមិនចំណុះរដ្ឋាភិបាល សភាជាតិ ព្រឹទ្ធសភា អង្គការ ស្ថាប័ន ឬបុគ្គលណាមួយឡើយ ហើយមានតួនាទីរកយុត្តិធម៌ជូនប្រជាពលរដ្ឋទាំងអស់ តាមផ្លូវច្បាប់ ដោយគ្មានការរើសអើង និងការស៊ីសំណូកសូកប៉ាន់។ ដូច្នេះដើម្បីធ្វើឱ្យមានយុត្តិធម៌ តុលាការត្រូវគោរពសិទ្ធិមនុស្សរបស់គូក្តីទាំងសងខាង និងត្រូវអនុវត្តការកាត់សេចក្តីដោយយោងទៅរកសិទ្ធិមនុស្សផងដែរ ។ ប្រជាពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសំរេចទាំងឡាយរបស់តុលាការ ដែលមានភស្តុតាងបង្ហាញថាមានការកាត់ក្តីដោយរំលោភសិទ្ធិមនុស្ស ។

**ក្រុមហ៊ុនឯកជន និងអង្គការសង្គម :** ផ្នែកទាំងនេះ ក៏មានការទទួលខុសត្រូវ និងកាតព្វកិច្ចផងដែរចំពោះសិទ្ធិមនុស្ស។ ពួកគេត្រូវតែគិតអំពីផលអាក្រក់ដែលប៉ះពាល់ដល់សិទ្ធិមនុស្សផងដែរ មិនមែនគិតតែការទាញយកផលប្រយោជន៍ពីមនុស្សតែម្យ៉ាងនោះទេ ។ ឧទាហរណ៍ ការចាក់សោបង្ខាំងកម្មករឱ្យនៅក្នុងរោងចក្រ និងបង្ខំឱ្យធ្វើការងារ ការមិនអនុញ្ញាតសំរាកថែទាំសុខភាព ឬមិនផ្តល់ការថែទាំសុខភាព ការបណ្តេញចេញពីការងារតាមអំពើចិត្ត ឬការកៀបសង្កត់បង្ខំឱ្យលះបង់ការងារដែលខ្លួនពេញចិត្ត។ល។ អំពើទាំងនេះ បានទាញយកផលចំណេញជាច្រើនពីមនុស្ស ប៉ុន្តែវាបានរំលោភសិទ្ធិមនុស្ស ។ បើយើងធ្វើតុល្យភាពរវាងសិទ្ធិមនុស្សទៅនឹងការទទួលខុសត្រូវ និងកាតព្វកិច្ចយើងឃើញថា គ្មានការទទួលខុសត្រូវ និងរំលោភលើកាតព្វកិច្ច ។

**ឧទាហរណ៍ខ្លះៗស្តីពីតុល្យភាពរវាងសិទ្ធិមនុស្ស កាតព្វកិច្ច និង ការទទួលខុសត្រូវ**

| សិទ្ធិមនុស្ស | កាតព្វកិច្ច | ការទទួលខុសត្រូវ |
|---|---|---|
| សិទ្ធិរស់រានមានជីវិត | - ការពារមិនឱ្យមានការសម្លាប់<br>- ថ្កោលទោសចំពោះអំពើសម្លាប់<br>- គោរពជីវិតអ្នកដទៃជានិច្ច ។ល។ | - មិននិយាយ/គិត/ប្រាថ្នាសម្លាប់ជីវិតអ្នកដទៃ<br>- សារភាពឬដឹងកំហុសពីការសម្លាប់<br>- មិនចូលរួមសម្លាប់ |
| សិទ្ធិសុខភាព | - ត្រូវទៅកាន់មន្ទីរពេទ្យ<br>- ត្រូវសាងសង់មន្ទីរពេទ្យ ។ល។ | - ខំលេបថ្នាំតាមលោកគ្រូពេទ្យប្រាប់<br>- មិនយកថ្លៃពីអ្នកក្រីក្រ ។ល។ |

## ការមិនរើសអើងនយោបាយ ឬអព្យាក្រឹតភាពរបស់មន្ត្រីរាជការ

ប្រជាពលរដ្ឋកម្ពុជានឹងគោរព ហើយមានជំនឿចំពោះមន្ត្រីរាជការ ប្រសិនបើបុគ្គលិកលក្ខណៈនៃមន្ត្រីនោះមានអព្យាក្រឹតភាពគ្រប់គ្រាន់ គឺមានន័យថា មិនប្រកាន់និន្នាការនយោបាយខាងណាមួយ ហើយអនុវត្តតាមតែវិជ្ជាជីវៈរបស់ខ្លួនដោយមិនរើសអើង ។ មន្ត្រីរាជការត្រូវសច្ចាស្មោះស្ម័គ្រចំពោះរដ្ឋធម្មនុញ្ញយកប្រយោជន៍ជាតិជាធំ មិនមែនគិតតែគណបក្សនយោបាយ ។ ការធ្វើខ្លួនឱ្យទៅជាមន្ត្រីអព្យាក្រឹតប្រកបដោយវិជ្ជាជីវៈ បុគ្គលម្នាក់ៗត្រូវតែទទួលស្គាល់ និងគោរពច្បាប់ដែលការពារសិទ្ធិមនុស្ស ហើយមិនត្រូវប្រព្រឹត្តបទល្មើស ឬអំពើរំលោភសិទ្ធិមនុស្សឡើយ ។ មន្ត្រីរាជការមានក្របខ័ណ្ឌពីរដោយឡែកពីគ្នាគឺ ក្របខ័ណ្ឌតាមអាណត្តិ (ឬក្របខ័ណ្ឌនយោបាយ) និងក្របខ័ណ្ឌអចិន្ត្រៃយ៍ (ឬក្របខ័ណ្ឌជាតិ) ។ ក្របខ័ណ្ឌអចិន្ត្រៃយ៍ ឬក្របខ័ណ្ឌជាតិជាក្របខ័ណ្ឌដែលមិនមានការប៉ះពាល់ពីការបោះឆ្នោត ហើយជាក្របខ័ណ្ឌទ្រទ្រង់នូវស្ថិរភាព សង្គម ដោយមិនយកបញ្ហានយោបាយមកលាយឡំនឹងតួនាទីរបស់ខ្លួន ដើម្បីជំរុញឱ្យល្បឿននៃការអភិវឌ្ឍន៍ សង្គមជាតិមិនរាំងស្ទះនៅពេលមានការផ្លាស់ប្តូរមេដឹកនាំរដ្ឋ ។ មន្ត្រីរដ្ឋបាលទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍មិនរើសអើង ជានិច្ចកាលធានាដល់ដំណើរការបោះឆ្នោតដោយសេរី ត្រូវមានការ បើកចំហដល់ពលរដ្ឋទាំងអស់រាប់បញ្ចូលទាំងអប្បភាគជន ដូចជាពួកជនជាតិចារ៉ាយ កាចក់ វៀតណាម ប្រាវ ចិន ចាម ។ល។ ដែលមានសិទ្ធិស្របច្បាប់ ចូលរួមសកម្មភាពសាធារណៈដទៃៗទៀត ដែលពាក់ព័ន្ធនឹងការងារដោយផ្ទាល់ខ្លួនគេក្តី និងដោយគំរោងអភិវឌ្ឍន៍រួមក្តីរបស់សហគមន៍គេ ជាពិសេសចូលរួមគណបក្សនយោបាយ ឬឈរឈ្មោះឱ្យគេបោះឆ្នោតឃុំ-សង្កាត់ ។

## ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

## អព្យាក្រឹតភាពក្នុងសកម្មភាពការងារ

**មាត្រា ៣៥ :** ត្រូវហាមឃាត់ដាច់ខាតដល់មន្ត្រីរាជការនូវប្រការខាងក្រោម :

១- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២- យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ ។

៣- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ ។

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាអភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជន ដោយផ្ទាល់ ឬដោយប្រយោល ។

៥-	បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយពត៌មាន ដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។

៦-	ប្រកបមុខរបរ បន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាន និងបទបញ្ញត្តិនៃមាត្រានេះ អាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយ ដែលមានចែងក្នុងមាត្រា៤០នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញា ដែលអាចកើតមានឡើងទៀតផង ។

**មាត្រា ៣៧ :** មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសំភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយដូចខាងក្រោម :

១-	ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២-	ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តិទាំងអស់នេះ ចាត់ទុកជាកំហុស និងការឆ្គាំឆ្គងនឹងវិជ្ជាជីវៈ ។

**មាត្រា ៣៨ :** អ្នករាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ ត្រូវទទួលខុសត្រូវពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៤០ :** ទណ្ឌកម្មខាងវិន័យមានដូចតទៅ :

**ទណ្ឌកម្មថ្នាក់ទី១**

ក-	ស្តីបន្ទោស

ខ-	ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ-	ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ-	លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់

**ទណ្ឌកម្មថ្នាក់ទី២**

ក- ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរៈវេលាមួយមានកំណត់ តែមិនត្រូវ ឱ្យលើសពី២ឆ្នាំក្នុងការតម្លើងឋានន្តស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាព ។

ខ- ដាក់ឱ្យនៅទំនេរគ្មានបៀវត្សរ៍ មិនឱ្យលើសពីមួយឆ្នាំ ។

គ- បន្ថយឋានន្តរស័ក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់ ។

ឃ- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ចប់ពីការងារដោយបង្ខំ ។

ង- បណ្តេញចេញពីមុខតំណែងរាជការ ។

## ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

## តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ-សង្កាត់

**មាត្រា ៤១ :** រដ្ឋបាលឃុំ-សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ ធនធាននានា ដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ-សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២ :** រដ្ឋបាលឃុំ-សង្កាត់ មានតួនាទីពីរប្រភេទ គឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ-សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

**មាត្រា ៤៣ :** ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ-សង្កាត់ មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ ។
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថានធនធានធម្មជាតិ វប្បធម៌បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់ អធ្យាស្រ័យទៅវិញទៅមក។
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ

**មាត្រា ៤៤** : ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ-សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ-សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥** : រដ្ឋបាលឃុំ-សង្កាត់ គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារប្រទេស
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀត ដែលមានចែងក្នុងច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា៤៦** : តួនាទី មុខងារ និងអំណាចរបស់ឃុំ-សង្កាត់ ដូចមានចែងក្នុងមាត្រា៤២.៤៣ និងមាត្រា៤៤ នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនឃុំ-សង្កាត់ របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើង ទាក់ទងសមត្ថកិច្ចរវាងឃុំ-សង្កាត់ ពីរ ឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាល ដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧** : តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ-សង្កាត់ ដូចមានចែងក្នុងមាត្រា៤២.៤៣.៤៤ និងមាត្រា៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀត ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨** : ឃុំ-សង្កាត់ មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ-សង្កាត់ ត្រូវធ្វើឡើងតាមរយៈដីកាឃុំ-សង្កាត់ សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួន ។

ដីកាឃុំ-សង្កាត់ ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ-សង្កាត់ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ក្នុងឃុំ-សង្កាត់របស់ខ្លួន នូវដីកាដែលបានសំរេចរួចហើយ ។

**មាត្រា ៤៩ :** ដីកាឃុំ-សង្កាត់ មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ-សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ-សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យប្រកាសនឹងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះ ជាលាយល័ក្ខអក្សរដល់ឃុំ-សង្កាត់សាមី និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០ :** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទម្រង់ និងបែបបទ ដើម្បីឱ្យឃុំ-សង្កាត់ រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ-សង្កាត់របស់ខ្លួន ។

**មាត្រា ៥១ :** ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តី ណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ-សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

មេឃុំ ចៅសង្កាត់ ដែលត្រូវបានក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។

**មាត្រា ៥២ :** ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់នៅតែ ទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការ ដែលបានធ្វើរួចហើយនោះឡើយ ។

# សិទ្ធិស្ត្រី

**វត្ថុបំណង:**

ក្រោយពីអ្នកអានបានអានចប់មេរៀននេះទៅ គេនឹងអាចវិភាគ និងបានយល់ថា :

១- សិទ្ធិស្ត្រីជាសិទ្ធិមនុស្ស និងសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី

២- ទស្សនៈស្ត្រីជាភេទទន់ខ្សោយ និងបង្វិលចង្ក្រានមិនជុំ មិនអាចមានតទៅទៀតឡើយ សំរាប់សង្គម ។

៣- អំពើហិង្សាក្នុងគ្រួសារជាអំពើល្មើសនឹងច្បាប់ ដែលត្រូវតែមានការផ្តន្ទាទោសតាមកំរិតកំហុសធ្ងន់ និងស្រាល ។

## ១. និយមន័យ

សិទ្ធិស្ត្រី គឺជាអំណាចរបស់ស្ត្រី ដែលធ្វើអ្វីបានតាមសមត្ថភាព លទ្ធភាពដោយអនុលោមទៅតាមច្បាប់ និងសីលធម៌ ។



## ២. សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស

បុគ្គលម្នាក់ៗ ទោះបីបុរស ឬស្ត្រីអាចមានគុណសម្បត្តិ សមត្ថភាព និងទេពកោសល្យខុសប្លែកគ្នា តែភាពខុសគ្នានេះ ពុំអាចកែប្រែតម្លៃជាមនុស្សបានឡើយ ។ ស្ត្រីជាមនុស្ស ដូចនេះសិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស ។

- **សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស**

( អនុម័តដោយមហាសន្និបាតជាន់ខ្ពស់អង្គការសហប្រជាជាតិ នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ )

**មាត្រា ១ :** មនុស្សទាំងអស់កើតមកមានសេរីភាព សមភាព ទាំងសេចក្តីថ្លៃថ្នូរ ទាំងសិទ្ធិ ។ មនុស្សទាំងនោះមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈតាំងពីកំណើត គប្បីប្រព្រឹត្តរវាងគ្នា និងគ្នាក្នុងស្មារតីភាតរភាពជាបងប្អូន ។

**មាត្រា ២ :** ដោយសំអាងលើសេចក្តីថ្លែងការណ៍នេះ មនុស្សទាំងអស់ មិនត្រូវបានគេបែងចែកឱ្យខុសពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍ ពណ៌សម្បុរ វណ្ណៈ អ្នកមាន ឬអ្នកក្រ ភាសា សាសនា មតិនយោបាយ ឬជាពលរដ្ឋរបស់ប្រទេសគ្មានឯករាជ្យក៏ដោយ ។

**មាត្រា ៦ :** ជនគ្រប់រូបសុទ្ធតែមានសិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្សពេញលក្ខណៈច្បាប់ ទោះបី នៅទីកន្លែងណាក៏ដោយ ។

**មាត្រា ៧ :** មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយច្បាប់ត្រូវតែគ្រប់គ្រង និងការពារមនុស្សឱ្យបានស្មើៗគ្នា ។

- **កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**

**មាត្រា ៣ :** រដ្ឋជាសមាជិកទាំងឡាយ ត្រូវធានាឱ្យមានសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការប្រាស្រ័យផលនៃសិទ្ធិពលរដ្ឋនិងនយោបាយដូចដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ។

- **ច្បាប់ស្តីអំពីអាពាហ៍ពិពាហ៍ និងគ្រួសារ**

**មាត្រា ២៩ :** ក្នុងគ្រួសារ ប្តី ប្រពន្ធ ត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ ។

**មាត្រា ៣០ :** ប្តី ប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល ។

**មាត្រា ៣៩ :** ប្តី ឬ ប្រពន្ធ អាចប្តឹងសុំលែងលះគ្នាកាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។ មូលហេតុជាអាទិ៍មានដូចខាងក្រោមនេះ :

១. ការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ ។

២. វាយដំយោរយៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ ។

៣. មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ ។

៤. អពលានុភាពនៃលិង្គ ។

៥. បែកគ្នាអស់រយៈពេលជាង ១ ឆ្នាំ ។

**មាត្រា ៤០ :** ប្តី ប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។

**មាត្រា ៥៩ :** ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថាស្ថានភាពរវាងប្តីប្រពន្ធមានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យាររយៈបាន គោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច តុលាការប្រជាជនត្រូវសំរេចអោយលែងលះគ្នា ។

**មាត្រា ៧៤ :** ឪពុក ឬម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន ។ កំរិតអាហារកិច្ចដែលត្រូវអោយទៅកូន ត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ទ្ធដែលលែងលះគ្នា ។ ក្នុងករណីដែលគូភាគីទាំងសងខាងមិនឯកភាពគ្នា តុលាការត្រូវសំរេចដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ ។ អាហារកិច្ចត្រូវផ្តល់អោយកូនរហូតដល់កូនមាននីតិភាព ។

- **អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ**

( ប្រកាសឡើងដោយអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ និងចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១ ប្រទេសកម្ពុជាបានចុះហត្ថលេខាចូលជាភាគីនៃច្បាប់នេះ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩២ ដោយឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា ) ។

**មាត្រា ៣ :** លើគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងវិស័យនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋជាភាគីទាំងឡាយត្រូវប្រកាន់យកវិធានការសមស្របនានា រួមទាំងបញ្ញត្តិច្បាប់ផងដែរ ដើម្បីធ្វើឱ្យមានការរីកចំរើនលូតលាស់ និងជឿនលឿនយ៉ាងពេញលេញរបស់នារីភេទក្នុងគោលដៅនានា អាចឱ្យនារីប្រើប្រាស់ និងទទួលបាននូវសិទ្ធិ ព្រមទាំងសេរីភាពជាគ្រឹះទាំងឡាយលើមូលដ្ឋានស្មើភាពនិងបុរស ។

- **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ៣១ :** ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

**មាត្រា ៣៤ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

**មាត្រា ៣៥ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

**មាត្រា ៣៦ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ការងារមេផ្ទះមានតម្លៃស្មើគ្នា និងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

**មាត្រា ៣៨ :** ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

យោងទៅតាមមាត្រាច្បាប់ដែលបានរៀបរាប់ខាងលើ សុទ្ធតែបានបង្ហាញឱ្យឃើញនូវជំនឿជាក់យ៉ាងមុតមាំថា ការទទួលស្គាល់នូវតំលៃ និងសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើគ្នារបស់មនុស្សរាល់រូប និងភាពមិនអាចប៉ះពាល់បាន គឺជាមូលដ្ឋាននៃសេរីភាព យុត្តិធម៌ សន្តិភាពក្នុងសកលលោក ។ ការមិនទទួលស្គាល់ និងមិនគោរពសិទ្ធិមនុស្សបាននាំឱ្យកើតមានអំពើសាហាវព្រៃផ្សៃដែលមនុស្សលោកក្តៅក្រហាយ និងស្អប់ខ្ពើម ។

ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានបានផ្តល់ឱ្យមនុស្សម្នាក់ៗ បានប្រើគុណសម្បត្តិសតិសម្បជញ្ញៈជាមនុស្ស ដើម្បីបំពេញតម្រូវការផ្នែកស្មារតី និងតម្រូវការដទៃទៀត ជាពិសេសគឺបានផ្តល់នូវការអភិវឌ្ឍន៍យ៉ាងពេញលេញដល់បុគ្គលគ្រប់រូប ក៏ដូចជាសង្គមជាតិទាំងមូល ។

ដូច្នេះក្នុងការរស់នៅប្រចាំថ្ងៃ និងសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលគ្រប់រូប ត្រូវតែបានគេគោរពគ្រប់ពេលវេលាទាំងអស់ ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ វណ្ណៈ អ្នកមាន អ្នកក្រ ភាសា សាសនា និន្នាការនយោបាយ ។

## ៣. តុល្យភាពផ្នែកភេទ

ភាពខុសប្លែកគ្នានៃភេទរវាងបុរស និងស្ត្រី មិនអាចយកមកធ្វើសំអាងពីភាពទន់ខ្សោយរបស់ស្ត្រី និងភាពខ្លាំងរបស់បុរសឡើយ ។ ភេទរបស់បុរស និងស្ត្រីបង្ហាញពីតុល្យភាពបន្តពូជពង្សមនុស្ស ដែលមានន័យថាបើគ្មានភេទទាំងពីរប្រសព្វគ្នាទេ ក៏មិនអាចបង្កើតមនុស្សបានដែរ ។ ភាពខ្លាំងខ្សោយមិនអាស្រ័យលើភេទទេ វាអាស្រ័យលើកត្តាច្រើនយ៉ាងទាក់ទងនឹងការហ្វឹកហាត់ផ្លូវកាយនិងផ្លូវចិត្ត ។

ស្ត្រីត្រូវបានគេបង្រៀនឱ្យមាន អាកប្បកិរិយាសុភាពទន់ភ្លន់ និងជាកម្មវត្ថុដែលត្រូវបានគេកំណត់ឱ្យធ្វើអ្វីបាន និងធ្វើអ្វីមិនបាន ព្រោះហេតុជាភេទស្រី ហើយផ្តល់ឱ្យបុរសនូវអំណាចដ៏ធំធេងក្នុងការសំរេចការងារផ្សេងៗ ដោយសំអាងហេតុមកពីបុរសមានភេទជាប្រុស ។ មានរឿងហេតុជាច្រើនដែលគេបានយកភេទមកសំអាង ដើម្បីកំណត់ចលនារវាងស្ត្រីនិងបុរស ពោលគឺស្ត្រីគួរធ្វើអ្វីនិងមិនគួរធ្វើអ្វី ហើយគេផ្តល់សកម្មភាពតិចតួចសំរាប់ស្ត្រី ។ ស្ត្រីមួយចំនួនបានព្រមទទួលយកនូវការងារដែលបុរសប្រាប់ពួកគេថាជាការងារស្រាលៗនៅក្នុងផ្ទះ ។ ស្ត្រីខ្លះបានគិតថា វាជាការល្អណាស់ និងស្រួលម្យ៉ាងដែរ ដែលបុរសត្រូវតែជាអ្នករ៉ាប់រងការងារធ្ងន់ៗ និងជាអ្នកត្រាច់ចររកប្រាក់ចិញ្ចឹមកូន និងប្រពន្ធ ស្ត្រីខ្លះក៏ចាប់មានជំនឿថា មិនគួររៀនចេះដឹងច្រើនពេកមែន ហើយក៏មិនគួរធ្វើការអ្វីដែលបុរសគួរធ្វើដែរ ។

មានស្ត្រីជាច្រើនបានទាមទារឱ្យគោរពសិទ្ធិរបស់ស្ត្រី គឺសិទ្ធិស្មើភាពគ្នារវាងបុរស និងស្ត្រី ប៉ុន្តែស្ត្រីខ្លះបានត្អូញត្អែរថា ការប្រើប្រាស់សិទ្ធិទាំងឡាយដូចជាបុរស ធ្វើឱ្យគេមានការហត់នឿយ និងលំបាកយ៉ាងខ្លាំង ពួកគេចង់បោះបង់សិទ្ធិខ្លះទៅវិញ ក្នុងអំឡុងដែលស្ត្រីឯទៀតកំពុងតែតស៊ូពុះពារយ៉ាងសកម្ម ដើម្បីឱ្យមានការគោរពដល់សិទ្ធិស្ត្រី ។ ប៉ុន្តែក៏មានបុរសខ្លះ បានបណ្តេញប្រពន្ធខ្លួនឱ្យចេញទៅរកការងារធ្វើនៅក្រៅផ្ទះ ដោយពាក្យទ្រគោះថា ស្ត្រីគួរតែប្រើប្រាស់សិទ្ធិមនុស្សដែលស្ត្រីមានដូចបុរស ។

ស្ត្រីមានសិទ្ធិចូលរួមក្នុងការអភិវឌ្ឍន៍ដូចបុរស ។ ស្ត្រីអាចធ្វើការងារក្នុងផ្ទះនិងក្រៅផ្ទះដូចជាបុរស។ បុរសត្រូវតែលះបង់នូវគំនិតថា ស្ត្រីជាភេទទន់ខ្សោយនិងបង្ខិលចង្រ្កានមិនជុំ ហើយត្រូវប្រគល់ការងារឱ្យស្ត្រីចូលរួមគ្រប់យ៉ាងដែលបុរសយល់ថា មានតែបុរសអាចធ្វើបាន ស្របគ្នានេះដែរ ស្ត្រីក៏ត្រូវបង្ហាញពីកម្លាំងកាយ និងសមត្ថភាពរបស់ខ្លួនចូលរួមក្នុងការងារនេះផងដែរ។ ស្ត្រីមិនគួរយល់ព្រមនឹងគំនិតឬជំនឿដែលថា នេះជាការងារប្រុសៗ មិនមែនការងារស្រីៗ។ ស្ត្រីត្រូវតែបញ្ចេញនូវសេចក្តីក្លាហាននិងទំនុកចិត្តរបស់ខ្លួន ដើម្បីបង្ហាញឱ្យឃើញថា បុរសអាចធ្វើអ្វីបាន ស្ត្រីក៏អាចធ្វើអ្វីនោះបានផងដែរ។ ជាការពិតណាស់ ស្ត្រីអាចបង្កើតភាពអស្ចារ្យជាច្រើនបានដូចបុរស និងជាប្រវត្តិសាស្ត្រផងដែរ។

## ៤. ការរើសអើងនឹងស្ត្រី

ការរើសអើងប្រឆាំងនឹងនារីភេទ គឺសំដៅលើការរំលោភលើគោលការណ៍សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ហើយនិងការរំលោភទៅលើគោលការណ៍គោរពភាពថ្លៃថ្នូរ លើសេរីភាពរបស់ស្ត្រីក្នុងវិស័យនយោបាយ ពលរដ្ឋសង្គម និងវប្បធម៌ ។

ស្ត្រីខ្មែរមិនបានចាប់អារម្មណ៍ទៅលើការរើសអើងប្រឆាំងស្ត្រីភេទទេ ដោយមូលហេតុច្រើនប្រការដូចជា :

### ក- ទស្សនៈសង្គមគ្រួសារកន្លងមក

ប្រជាពលរដ្ឋខ្មែរភាគច្រើនឱ្យតំលៃទាបទៅលើស្ត្រី ដោយឪពុកម្តាយតែងគិតថា កូនស្រីមិនបាច់រៀនសូត្រចេះដឹង វែងឆ្ងាយទេ ព្រោះទោះជាយ៉ាងណាក៏កូនស្រីវិលកន្ទុយចង្ក្រានមិនជុំដដែល ។ ភារកិច្ចរបស់ស្ត្រី គឺដាំស្ល ថែទាំផ្ទះសំបែង ថែរក្សាបុត្រធីតា បំរើប្តី បង្កើត និងចិញ្ចឹមកូនគ្រប់គ្រាន់ណាស់ទៅហើយ ព្រោះមានប្តីជា អ្នករកស៊ីចិញ្ចឹម ។

ដោយខ្លាចខុសប្រពៃណី ឪពុកម្តាយត្រូវបង្ខាំងកូនស្រី ដែលឋិតនៅក្នុងវ័យជំទង់មិនឱ្យទៅឆ្ងាយពីផ្ទះ ។ ចំណុចទាំងនេះ គឺជាឧបសគ្គមួយ ដែលរារាំងកូនស្រីមិនឱ្យបន្តការសិក្សាវែងឆ្ងាយបាន ។

កូនស្រីមិនបាច់រៀនចេះដឹងអ្វីទេ ព្រោះការចេះដឹងច្រើននាំឱ្យនាងមានលទ្ធភាពសរសេរសំបុត្រឆ្លើយឆ្លងគ្នា ជាពិសេសរៀនច្រើនពេកនាំឱ្យឆាប់ចាស់ពិបាករកគូស្រករ ដូចពាក្យចាស់ពោលថា " *អ្នកក្រមិនហ៊ាន អ្នកមានមិនចូល* " ។

គ្រួសារខ្មែរមានទម្លាប់មួយគឺ បើសិនកូនស្រី និងកូនប្រុសរៀនថ្នាក់ជាមួយគ្នា គ្រួសារមានសមត្ថភាពសំរាប់តែឧបត្ថម្ភកូនម្នាក់ ដូច្នេះអ្នកដែលត្រូវបញ្ឈប់ពីការសិក្សាមុនគេគឺកូនស្រី ព្រោះគាត់យល់ថាបើបញ្ឈប់កូនស្រី នឹងអាចជួយការងារផ្ទះបានផង ហើយបើរៀនច្រើនក៏គ្មានប្រយោជន៍ដែរ ព្រោះជៀសពីចង្ក្រានជើងឆ្នាំងមិនរួច ។

## ខ- ប្រពៃណី និង ទំនៀមទំលាប់ខ្មែរ

យោងតាមទំនៀមទំលាប់ ប្រពៃណីស្ត្រីខ្មែរ ត្រូវតែគោរពប្តី គោរពម៉ែឪ ដូចពាក្យថា " *ទំមិនធំជាងនាឡិទេ* " បានន័យថា " *កូនមិនធំជាងឪពុក ម្តាយ* " ។

## គ- ទស្សនៈសង្គមកន្លងមក

- ស្ត្រីត្រូវតែចុះចាញ់និងគោរពប្តីដោយឥតលក្ខខណ្ឌទើបបានសុខ
- ស្ត្រីជាភេទទន់ខ្សោយ យកស្មើបុរសមិនបានទេ
- ស្ត្រីមិនចាំបាច់ទាមទារការងារដឹកនាំក្នុងសង្គមទេ ព្រោះប្រាជ្ញាអន់
- ស្ត្រីមិនចាំបាច់ទាមទារសិទ្ធិនយោបាយទេ ព្រោះគ្មានលទ្ធភាពដូចបុរស

ទាំងអស់នេះជាគំនិតនិងទម្លាប់មិនជឿនលឿន ដែលនាំអោយស្ត្រីខ្មែររស់នៅក្រោមការគៀបសង្កត់របស់សង្គម និង មនុស្សប្រុស ។

## ឃ- ច្បាប់ទប់ស្កាត់ការរើសអើងប្រឆាំងនឹងស្ត្រី

**មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ**

ការរើសអើង គ្រប់ប្រភេទ ប្រឆាំងនឹង ស្ត្រីភេទ ត្រូវបំបាត់ចោល ។

**មាត្រា ២ នៃអនុសញ្ញា ស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ**

រដ្ឋជាភាគីទាំងឡាយ ផ្តន្ទាទោសការរើសអើង ប្រឆាំងនារីភេទនៅក្នុង គ្រប់ទម្រង់របស់វាទាំងឡាយ និងឯកភាពអនុវត្តតាម គ្រប់មធ្យោបាយដែលសមស្រប និងដោយឥតបង្អែរបង្អង់នូវគោល

នយោបាយបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ ហើយនៅក្នុងទិសដៅនេះ សន្យាថា :

ក- បញ្ចូលគោលការណ៍នៃសមភាពរវាងបុរស និងនារីទៅក្នុងរដ្ឋធម្មនុញ្ញ និងបញ្ញត្តិច្បាប់នានាឯទៀតដែលសមស្រប បើសិនជាគោលការណ៍នេះមិនទាន់ត្រូវបានបញ្ចូលនៅឡើយទេនោះ ហើយនិងធានាតាមរយៈច្បាប់ និងរាល់មធ្យោបាយនានា ដែលសមស្របនូវវិធីការធ្វើឱ្យចេញជាជាក់ស្តែងនូវគោលការណ៍នេះ ។

ខ- អនុម័តនូវបញ្ញត្តិ និងវិធានការផ្សេងៗទៀតដែលសមស្រប ដើម្បីហាមឃាត់រាល់ការរើសអើងប្រឆាំងនារីភេទ ។

គ- លើកឡើងនូវកិច្ចគាំពារតាមផ្លូវច្បាប់នូវសិទ្ធិស្មើភាពនិងបុរសរបស់នារីភេទ ហើយនិងធានានូវកិច្ចគាំពារនារីដ៏មានប្រសិទ្ធភាព តាមរយៈតុលាការជាតិ និងរាល់ស្ថាប័នសាធារណៈផ្សេងៗ ដែលមានសមត្ថកិច្ចប្រឆាំងរាល់អំពើរើសអើងទាំងអស់ ។

ឃ- តមមិនព្រមប្រព្រឹត្តិនូវទង្វើ ឬការអនុវត្តន៍សកម្មភាពរើសអើងប្រឆាំងនារីភេទឡើយ ហើយនិងត្រួតពិនិត្យឱ្យច្បាស់ថា អាជ្ញាធរ និងស្ថាប័នសាធារណៈទាំងឡាយនិងធ្វើសកម្មភាពសមស្របទៅតាមកាតព្វកិច្ចនេះ ។

ង- នឹងប្រកាន់យកនូវវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ចោលនូវការរើសអើងប្រឆាំងនារីភេទ ដែលធ្វើឡើងដោយបុគ្គលអង្គការ ឬសហគ្រាសណាមួយក្តី ។

ច- នឹងប្រកាន់យកនូវវិធានការសមស្រប រួមទាំងបញ្ញត្តិច្បាប់ផង ដើម្បីផ្លាស់ប្តូរ ឬលុបចោលនូវច្បាប់ បទបញ្ញត្តិ ទម្លាប់ និងការអនុវត្តន៍ទាំងអស់ណា ដែលជាការរើសអើងប្រឆាំងនារីភេទ ។

ឆ- លុបចោលនូវរាល់បញ្ញត្តិព្រហ្មទណ្ឌនានារបស់ប្រទេស ដែលបង្កឡើងជាការរើសអើងប្រឆាំងនារីភេទ ។

## ✱ កាតព្វកិច្ចចំពោះសិទ្ធិស្ត្រី

ដើម្បីឱ្យនិន្នាការសាកលភាពនៃសិទ្ធិមនុស្ស ដែលបានឱ្យតម្លៃស្ត្រីថា "*ស្ត្រីជាមាតានៃលោក*" មានអត្ថន័យពេញលេញនោះ កាតព្វកិច្ចទាំងនេះត្រូវតែអនុវត្តឱ្យបាន (ទាំងក្នុងវិស័យរដ្ឋ ឯកជន និងគ្រួសារ) នូវទស្សនៈមួយចំនួនដូចខាងក្រោម :

- ស្ត្រីត្រូវទទួលបាននូវឱកាសច្រើនជាងបុរស ក្នុងការជ្រើសរើសមុខរបរណាដែលត្រូវការប្រើបញ្ញាច្រើនជាងការងារណាដែលប្រើកំលាំង ។

- ស្ត្រីត្រូវតែទទួលបាននូវការគាំពារពិសេសដោយច្បាប់ ទៅលើលំហែមាតុភាពធានានូវការប្រើកម្លាំងពលកម្មស្ត្រីមានផ្ទៃពោះនៅតាមការដ្ឋានសំណង់ រោងចក្រ វាយនភ័ណ្ឌ ឬនៅតាមផ្សារ និងពលកម្មផ្សេងៗទៀតរហូតដល់ថ្ងៃសំរាលកូន ។
- ស្ត្រីក៏ត្រូវបានធានាដោយរដ្ឋ និងសង្គមនូវការបាត់បង់ការងារ ដោយមូលហេតុនៃការលំហែមាតុភាព ។
- ស្ត្រីត្រូវបានយកចិត្តទុកដាក់ និងជាកាតព្វកិច្ច របស់រដ្ឋ និងម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាសនានា ដើម្បីធានាសិទ្ធិមានជីវិត និងសុខទុក្ខមាតា ។
- ស្ត្រីក៏ត្រូវទទួលបាននូវការគោរព ការការពារប្រពៃណីទំនៀមទម្លាប់ល្អៗរបស់គេក្នុងការងារទំនាក់ទំនង ដោយការប្រើនូវពាក្យផ្អែមល្ហែម ទន់ភ្លន់ សុភាពរាបសារ ក្នុងសេចក្តីថ្លៃថ្នូរ ប្រកបដោយសីលធម៌ខ្ពង់ខ្ពស់ និងម៉ឺងម៉ាត់ជានិច្ច ពីស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ទោះតាមរូបភាពអ្វីក៏ដោយ ។

## ៥. សិទ្ធិកុមារ

### ១. តើកុមារជាមនុស្សប្រភេទណា?

*កុមារគឺជាមនុស្សមានអាយុក្រោម១៨ឆ្នាំ លើកលែងតែអាយុពេញវ័យ* ។ នេះជាការកំណត់ដោយអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលយកអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ។



កុមារត្រូវបានចាត់ទុកជាបុគ្គលដែលកើតមកភ្ជាប់ជាមួយនូវសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរស្មើៗគ្នា ក្នុងនាមជាមនុស្ស ។ មានប្រការខ្លះដែលគួរជៀសវាងដូចជា ការប្រកាន់ភេទ ពណ៌សម្បុរ ភាសា ជំនឿសាសនា ដើមកំណើតជាតិ ឋានៈសង្គម ឬស្ថានភាពដទៃ ។

**ខ.សិទ្ធិសំខាន់ៗរបស់កុមារ**

យោងតាមគោលការណ៍១០យ៉ាង ក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ និងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ សិទ្ធិសំខាន់៤ របស់កុមារ :

- *សិទ្ធិរស់រានមានជីវិត*

សិទ្ធិរស់រានមានជីវិតជាសិទ្ធិមនុស្សរបស់កុមារ និងគ្មាននរណាម្នាក់អាចដកហូតសិទ្ធិនេះពីកុមារបានឡើយ ។ គឺកុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សំរាប់ការរស់នៅ ដូចជា ចំណីអាហារមានជីវជាតិ មានឈ្មោះ និងមានសញ្ជាតិ ការបង្ការនិងព្យាបាលសុខភាព សំលៀកបំពាក់ ជំរកស្នាក់នៅសមរម្យ និងមានជីវភាពគ្រប់គ្រាន់ ព្រមទាំងទទួលការថ្នាក់ថ្នម អំពីឳពុកម្តាយ អាណាព្យាបាលនិងសង្គម ។ កុមារមិនត្រូវទទួលរងការវាយធ្វើបាប ឬទារុណកម្មឡើយ ។

មាតា-បិតាត្រូវយល់ផងដែរថា សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ និងសហគមន៍អន្តរជាតិ ក៏មានចំណែកទទួលខុសត្រូវចំពោះសិទ្ធិរស់រានរបស់កុមារផងដែរ មានន័យថាជីវិតកូនរបស់អ្នកស្ថិតនៅក្រោមកិច្ចការពាររបស់សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ និងសហគមន៍អន្តរជាតិ។

ឳពុកម្តាយអាចរងការប្តឹងផ្តល់ពីសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ និងសហគមន៍អន្តរជាតិ ចំពោះអំពើដែលឳពុក-ម្តាយបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។

ឳពុក-ម្តាយអាចប្តឹងបរិហារ ប្តឹងតវ៉ាប្រឆាំងនឹងអាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ ឬបុគ្គលិកនៃអាជ្ញាធរទាំងនេះ អំពីការមិនយកចិត្តទុកដាក់ ឬមិនផ្តល់កិច្ចការពារ ឬបានរំលោភលើសិទ្ធិរស់រានរបស់កុមារ ។

- *សិទ្ធិទទួលបានកិច្ចការពារពិសេស និងសិទ្ធិពិសេស*

កុមារត្រូវទទួលបាននូវការការពារពិសេស និងសិទ្ធិពិសេស ។ ឧទាហរណ៍ មាតា-បិតា ត្រូវតាមមើលថែរក្សានិងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានាដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេព

កាមគុណលើកុមារ ការធ្វើអាជីវកម្មលើកុមារ ការលក់ដូរកុមារ និងអំពើដទៃៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍ធំបំផុតរបស់កុមារ ។

ឪពុក-ម្តាយត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារឯទៀតៗ ពីការរំលោភទាំងឡាយដែលអាចកើតមានពីអាជ្ញាធរមូលដ្ឋាន ឬពីអាជ្ញាធរជាតិ។ គេអាចបង្កើតសមាគមមាតា-បិតាក្នុងសហគមន៍មូលដ្ឋានក្នុងគោលបំណងការពារសិទ្ធិកុមារ។ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរជាតិក៏មានបន្ទុកលើកស្ទួយ និងការពារកុមារពីការរំលោភនានា ដែលអាចប្រព្រឹត្តដោយអ្នកអាណាព្យាបាលរបស់កុមារ និងអ្នកមានអំណាចមកលើកុមារផ្សេងៗទៀតផងដែរ។

- *__សិទ្ធិក្នុងការចូលរួម__*

កុមារមានសិទ្ធិចូលរួមបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាព ដែល មានឥទ្ធិពលដល់ដំណើរជីវិតរបស់គេ ចូលរួមក្នុងសមាគម និងការប្រជុំនានា និងចូលរួមទទួល និងផ្សព្វផ្សាយពត៌មាន អានសៀវភៅ កាសែត ទស្សនាវដ្តី ស្តាប់វិទ្យុ មើលទូរទស្សន៍... ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណរិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ ។

- *__សិទ្ធិក្នុងការអភិវឌ្ឍន៍__*

កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សា នៅសាលារៀន និងនៅផ្ទះ ឬក្នុងសហគមន៍ ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាពឱ្យបានកើតខ្ពស់បំផុត ។

## ៦. ការពង្រត់ ជួញដូរ និងការធ្វើអាជីវកម្មលើមនុស្ស

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន អំពើពង្រត់ អំពើលក់ដូរនិងអំពើដែលធ្វើអាជីវកម្មលើមនុស្សត្រូវក្លាយទៅជាបញ្ហាកាន់តែធំទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ។

### ក_និយមន័យ

*__អំពើពង្រត់មនុស្ស__* គឺជាអំពើចាប់កុមារ បុរស ឬស្ត្រីដោយការប្រើកម្លាំង ឬការបោកបញ្ឆោតជាថ្នូរសំរាប់យកប្រាក់លោះ ឬក៏សំរាប់លក់ឱ្យធ្វើជាពេស្យាចារ ឬកម្មករធ្វើការដោយបង្ខំ ។

*អំពើលក់ដូរមនុស្ស* គឺជាអំពើដឹកជញ្ជូន ឬប្តូរកុមារ ឬស្ត្រី ឬបុរស សំរាប់ការធ្វើពេស្យាកម្ម ឬសំរាប់ធ្វើការងារ ដោយបង្ខិតបង្ខំ តាមវិធីលួងលោម បោកបញ្ឆោត ទិញ និងលក់ ។



*អំពើធ្វើអាជីវកម្មលើមនុស្ស* គឺមនុស្សម្នាក់ ឬក្រុមមនុស្សច្រើននាក់ ឬពាណិជ្ជកររកស៊ី ដោយសារការបង្ខំកុមារ ស្ត្រី ឬបុរសឱ្យធ្វើជាពេស្យា ឬឱ្យធ្វើការងារដោយបង្ខំ ។ ចំពោះហេតុផលផ្សេងៗទៀត កុមារ ស្ត្រី ឬបុរស ត្រូវបានគេបង្ខំឱ្យធ្វើការងារ ដែលគ្មានសុវត្ថិភាព ឬការងារដែលគ្រោះថ្នាក់ ឬពួកគេត្រូវបានគេទិញ ឬលក់ ដើម្បីឱ្យធ្វើជាកម្មករផ្លូវភេទ ជាកម្មករសំណង់ កម្មកររោងចក្រ ឬជាអ្នកបំរើក្នុងផ្ទះ ។ល។ អ្នកដែលផ្តល់លុយកាក់ ដើម្បីរួមភេទជាមួយកុមារ ដែលមានអាយុក្រោម១៨ឆ្នាំ ក៏ជាទំរង់មួយនៃការធ្វើអាជីវកម្មដែរ ។

### ខ_ការបោកបញ្ឆោត

នៅប្រទេសកម្ពុជាបច្ចុប្បន្ន ការបោកបញ្ឆោតវាហាក់ដូចជារឿងធម្មតាទៅហើយ ជាពិសេសការបោកប្រាស់នេះ យើងឃើញកើតមានច្រើននៅតាមជនបទដាច់ស្រយាល ព្រោះពួកគេទាំងនោះខ្វះការអប់រំ ។ ការបោកប្រាស់នេះ ធ្វើឡើងតាមរយៈការជ្រើសរើសស្ត្រី និងកុមារពីជនបទយកមកក្រុងភ្នំពេញ ឬទៅក្រៅប្រទេស ដោយសន្យាថារកការងារឱ្យធ្វើ ដូចជាទៅធ្វើការនៅក្នុងរោងចក្រកាត់ដេរ ទៅដាំបាយឱ្យគេ

ទៅជួយលក់របស់របរនៅក្នុងហាង ។ល។ ការបោកប្រាស់នេះ ធ្វើឡើងតាមបែបលួងលោម ទាក់ទាញ ការនិយាយភូតកុហក ឬតាមការបង្កើតចំណងស្នេហា ដើម្បីឱ្យពួកគេធ្លាក់ចូលទៅក្នុងការព្រមព្រៀង ។

**គ_វិធានការទប់ស្កាត់នូវអំពើពង្រត់ និង ជួញដូរមនុស្ស**

✱ ស្ថានភាពក្នុងគ្រួសារ

- ឪពុក ម្តាយគួរខិតខំរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីឱ្យកូនប្រុស ស្រីបានទៅសាលារៀន ។
- ជៀសវាងអំពើហិង្សាក្នុងគ្រួសារ ព្រោះហិង្សានាំមកនូវភាពអពមង្គល ភាពហិនហោចទ្រព្យសម្បត្តិ និង ការព្រាត់ប្រាស។
- មិនត្រូវជឿពាក្យបញ្ចុះបញ្ចូល ពីអ្នកធ្លាប់ស្គាល់ពីមុនមក ដូចជា ( អ្នកភូមិជងរបងជាមួយ ដែលបានចេញពីភូមិកំណើតយូរឆ្នាំ ) ។
- ការយកកូនលក់ឱ្យធ្វើជាស្រីពេស្យាចារ ឬឱ្យទៅជនណាអ្នកបំរើការសប្បាយនោះ វាជាអំពើអាក្រក់បំផុត ដែលសង្គមជាតិស្អប់ខ្ពើម ហើយវាជាការបំផ្លាញអនាគតកូនខ្លួនឯង ។ នៅពេលខ្លះនាងមិនអាចទ្រាំទ្រនឹងអំពើទាំងនោះបាន ក៏សំលាប់ខ្លួនដើម្បីបញ្ចប់ជីវិតដ៏លាមកនេះ ។
- មាតា បិតាគ្រប់រូបត្រូវយល់ថា ប្រាក់មិនអាចទិញអាយុជីវិតមនុស្ស ដែលបាត់បង់ហើយនោះបានមកវិញទេ ។
- ឪពុក ម្តាយមិនគួរបណ្តោយឱ្យកូនស្រីរបស់ខ្លួន មករកការងារធ្វើនៅឯទីក្រុងទេ ព្រោះកូនស្រីនៅតាមជនបទភាគច្រើនមិនសូវមានការអប់រំ ហើយតែងតែធ្លាក់ចូលក្នុងល្បិចបោកប្រាស់របស់ជនខិលខូចយកទៅលក់នៅឯផ្ទះបន ។

✱ ស្ថានភាពក្នុងសង្គម

- បំបាត់ភាពអវិជ្ជា ដោយបង្កើតសាលារៀន និងបណ្តុះបណ្តាលគ្រូឱ្យបានច្រើន រហូតដល់ជនបទដាច់ស្រយាល ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រ មានសិទ្ធិចូលរួម ។
- ផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ ដល់ជនណាដែលប្រកបអាជីពចាប់ពង្រត់ជួញដូរភេទនិងបង្កើតបនស្រីពេស្យា។
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យដល់តំបន់ជនបទដាច់ស្រយាល។
- បំបាត់ភាពអត់ការងារធ្វើនៅក្នុងសង្គម។

- បង្កលក្ខណៈងាយស្រួលឱ្យប្រជាជនប្រកបរបរកសិកម្មដោយសុវត្ថិភាព។

✸ **តាមផ្លូវច្បាប់**

- **ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស**

**មាត្រា ៣**

ជនណាអូសទាញមនុស្ស ទោះបីស្រី ឬប្រុស អនីតិជន ឬនីតិជនមានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោមសន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួន សុខចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែង ឬប្រើថ្នាំសណ្ដំស្មារតី និងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជន អាយុតិចជាង១៥ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំដល់២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញ ឬទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្ដល់ប្រាក់ ឬផ្ដល់មធ្យោបាយផ្សេងៗសំរាប់ប្រព្រឹត្តិបទល្មើស ។

មធ្យោបាយដឹកជញ្ជូន សំភារៈ និងទ្រព្យសម្បត្តិប្រើប្រាស់ក្នុងពេលប្រព្រឹត្តិបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៤**

ជនណាដែលបានប្រព្រឹត្តអំពើអនាចារលើអនីតិជនអាយុក្រោម១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្ដី ឬដោយទិញក្មេងនោះពីអ្នកដទៃក្ដី ឬទិញពីជនជាមេពេស្យាក្ដី ជននោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំដល់២០ឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវយកអតិបរមានៃទោសមកអនុវត្ត ។

តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្ដន្ទាបន្ថែមលើមូលទោសខាងលើនេះបាន ។

- **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ៤៦**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីជនបទ ដែលគ្មានទីពឹង បានទទួលការងារបត្តម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា៤៨**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុញ្ញាស្តីពីកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

## ✱ វិធានការទប់ស្កាត់

ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវរាល់ការរំលោភសិទ្ធិចំពោះកុមារ គ្រួសារ សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវ :

- សិក្សាស្វែងយល់នូវខ្លឹមសារ ដែលមានចែងនៅក្នុងអនុសញ្ញា ស្តីពីសិទ្ធិកុមារ
- ធ្វើការផ្សព្វផ្សាយអំពីសិទ្ធិកុមារ ឱ្យបានទូលំទូលាយនៅក្នុងមូលដ្ឋាន និងសហគមន៍របស់ខ្លួន
- កាត់បន្ថយឱ្យទាបបំផុតនូវវិភាគទានពីសិស្សានុសិស្សក្នុងឱកាសបវេសនកាល ដើម្បីធ្វើឱ្យកុមារា កុមារី ជាកូនអ្នកក្រីក្រ មានលទ្ធភាពចូលរៀនបាន ។

- មានផែនការ សកម្មភាព និងចាត់វិធានការទប់ស្កាត់ និងបង្ក្រាបនូវរាល់បាតុភាពនៃអំពើពង្រត់ជួញដូរ កេងប្រវ័ញ្ចពលកម្មលើកុមារឱ្យមានប្រសិទ្ធភាព ។
- មានផែនការ និងវិធានការឱ្យបានម៉ឺងម៉ាត់ចំពោះឪពុក ម្តាយ គ្រួសារ ឬអាណាព្យាបាលដែលបញ្ឈប់កូនមិនឱ្យទៅសាលារៀន ក្នុងបំណងកេងប្រវ័ញ្ចលើពលកម្មរបស់កូន ។
- មានផែនការជួយឧបត្ថម្ភចំពោះកុមារ ក្នុងបន្ទុកគ្រួសារក្រីក្រ ដែលពុំមានលទ្ធភាពបញ្ជូនកូនទៅសាលា ដើម្បីមានឱកាសទៅរៀនវិញ ។
- ផ្តួចផ្តើមគំនិត ដើម្បីបង្កើតមណ្ឌលសុខភាព និងសម្ភពប្រកបដោយគុណភាព
- អប់រំសីលធម៌ជាប្រចាំដល់កុមារ ជាពិសេសនៅតាមសាលារៀន និងតាមគ្រួសារ
- លើកកំពស់ជានិច្ច នូវស្មារតីប្រុងប្រយ័ត្ន និងទប់ស្កាត់រាល់អំពើ និងទម្លាប់ ដែលរំលោភទៅលើសិទ្ធិកុមារ

## ៧. អំពើហិង្សាក្នុងគ្រួសារ

### ក. និយមន័យ

*អំពើហិង្សាក្នុងគ្រួសារគឺជាអំពើប្រព្រឹត្តឡើងដោយសមាជិកណាម្នាក់ ឬច្រើននាក់ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ផ្លូវកាយ ឬផ្លូវចិត្តលើនរណាម្នាក់ ឬ ច្រើននាក់ដែលរស់នៅក្នុងគ្រួសារតែមួយជាមួយគ្នា ។*

### ខ. ប្រភេទនៃអំពើហិង្សា

- ***ការរំលោភផ្នែករាងកាយ*** ការវាយដំ ទាត់ធាក់ រុញច្រាន សុទ្ធតែជាអំពើប្រព្រឹត្តទៅដោយការមើលងាយមើលថោកចំពោះសមាជិកគ្រួសារណាម្នាក់ ។
- ***ទង្វើធ្វើអោយឈឺចាប់ផ្លូវចិត្ត*** គឺជាទង្វើដែលបណ្តាលឱ្យមានភាពគ្រាំគ្រាផ្នែកផ្លូវចិត្ត តាមរយៈនៃការប្រើពាក្យសំដីប្រមាថ គំរាមកំហែង បំបិទសិទ្ធិនានានៅក្នុងគ្រួសារ ។
- ***ការបង្ខំរំលោភសេពសន្ថវៈ*** ជាទង្វើដែលចាប់បង្ខំអោយរួមរ័កជាមួយគ្នា ។ មានពេលខ្លះស្ត្រីដែលជាប្រពន្ធត្រូវទទួលរងនូវការវាយដំយ៉ាងធ្ងន់ធ្ងរពីសំណាក់ប្តី ព្រោះតែពុំអាចបំពេញបំណងប្តីបាន ។ មានបុរសមួយចំនួនយល់ថា ស្ត្រីគឺជាទ្រព្យសម្បត្តិ ឬជាកម្មសិទ្ធិផ្តាច់មុខរបស់ប្តី ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលអាចយកមកបំរើកាមតណ្ហាពេលណាក៏បានតាមដែលខ្លួនត្រូវការ ។

## គ. ផលវិបាកនៃអំពើហិង្សា

អំពើហិង្សាក្នុងគ្រួសារជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារទាំងមូល គឺមិនត្រឹមតែសមាជិកណាម្នាក់រងគ្រោះប៉ុណ្ណោះទេ កុមារក៏ត្រូវទទួលរងនូវទុក្ខសោកទាំងនេះដែរ ដូចជា :

- ប៉ះពាល់ដល់សតិបញ្ញាស្មារតី
- ប៉ះពាល់ដល់សុខភាព
- ប៉ះពាល់ដល់ជីវភាពគ្រួសារ
- ប៉ះពាល់ដល់ការរស់នៅរបស់កូន
- ប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច



- ប្តីវាយប្រពន្ធ នាំអោយ:
    - ប្តីជាប់គុក
    - ប្រពន្ធដេកពេទ្យ
    - កូនមិនបានទៅសាលារៀន ដើររើសអេតចាយ
    - កូនគ្មានអាហារ គ្មានជម្រក




## ✸ វិធានការទប់ស្កាត់តាមផ្លូវច្បាប់

**ច្បាប់ព្រហ្មទណ្ឌអន្តរកាល ស្តីពី បទឧក្រិដ្ឋ**

**មាត្រា ៣១ : ឃាតកម្មគិតទុកជាមុន**

១. ជនណាដែលសម្លាប់ ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬ ដោយបានរៀបចំការពួនស្ទាក់ ឬ ដែលបានសម្លាប់ ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ២០ឆ្នាំ។

២. ការគិតទុកជាមុន គឺជាគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់ គឺជាការឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ ។

**មាត្រា ៣២ : អំពើមនុស្សឃាតដោយចេតនា**

ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនាដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា៣១ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវ

ជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី៨ឆ្នាំ ទៅ១៥ឆ្នាំ ។

**មាត្រា ៣៣ : បទរំលោភសេពសន្ថវៈ**

១. ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀតទោះជាភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី៥ឆ្នាំ ទៅ១០ឆ្នាំ ។

២. បទរំលោភសេពសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការ

សេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្ត គឺដាក់គុកជាបទឧក្រិដ្ឋពី១០ឆ្នាំ ទៅ១៥ឆ្នាំ ។

**មាត្រា ៤១ : អំពើបង្ករបួសដោយចេតនា**

ជនណាវាយតប់ បណ្តាលអោយមានរបួស ដែលនាំអោយពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។

បើពិការភាពបណ្តោះអាសន្ននោះតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី៦ខែ ដល់២ឆ្នាំ ។

- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុកពី២ខែ ទៅ១ឆ្នាំ ។
- បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។

**មាត្រា ៤២ : អំពើបៀតបៀនកេរ្តិ៍ខ្មាស**

១. ជនណាដែលបៀតបៀនដល់កេរ្តិ៍ខ្មាស់នៃជនម្នាក់ទៀត ដែលមានភេទដូចគ្នា ឬមិនដូចគ្នា ដោយប្រព្រឹត្តទៅលើជននោះ តាមការស្ទាប អង្អែល ឬអំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ

ប៉ុន្តែពុំដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនកេរ្តិ៍ខ្មាស់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៣ឆ្នាំ ។

២. បើការបៀតបៀនដល់កេរ្តិ៍ខ្មាស់នោះ ធ្វើឡើងដោយការបន្លំ ដោយអំពើហិង្សា ដោយការគំរាមកំហែង

បើអ្នករងគ្រោះមានអាយុតិចជាង១៦ឆ្នាំ ឬអ្នកប្រព្រឹត្តអំពើនោះថា អ្នកមានអំណាច លើជនរងគ្រោះ ក៏វិតផ្តន្ទាទោសត្រូវទ្វេមួយជាពីរ ។

៣. នឹងត្រូវផ្តន្ទាទោសដាក់គុកពី២ឆ្នាំ ទៅ៦ឆ្នាំដែរ ចំពោះជនណាដែលបានល្បួងអូសទាញ ឬបង្វែងគំនិតអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ ។

**មាត្រា ៦៣ :ការបរិហាកេរ្តិ៍ និងការជេរប្រមាថ**

១. គ្រប់ការពោលអះអាង ឬគ្រប់ការទម្លាក់កំហុសដោយសុទ្ធចិត្ត នូវអំពើជាកំណត់ណាមួយ ដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហារកេរ្តិ៍ ។ ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវការពោលអះអាងនោះ ឬការទម្លាក់កំហុសនោះ ត្រូវមានទោស ទោះបីសំដៅលើជនណាមួយ ដោយមិនចេញឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថា តាមសម្រែកតាមការគំរាមកំហែង តាមការសរសេរ ឬតាមការបោះពុម្ពតាមផ្ទាំងបដារ ឬប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន៍ដែលជាប់ចោទ ។ គ្រប់ការពោលអះអាង ឬការទម្លាក់កំហុស ដែលអ្នកនិពន្ធ អ្នកសារពត៌មាន អ្នកទទួលខុសត្រូវខាងការផ្សាយ អ្នកទទួលខុសត្រូវខាងការបោះពុម្ពផ្សាយ នាយកកម្មវិធីដែលដឹងថាមិនពិត ហើយនៅតែផ្សាយ បោះពុម្ពផ្សាយ សរសេរ ឬផ្សព្វផ្សាយ ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺជាការបរិហាកេរ្តិ៍ ។

២. គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

៣. ការបរិហាកេរ្តិ៍ ឬការជេរប្រមាថ ប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដែលមានចែងក្នុងមាត្រា៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី៨ថ្ងៃ ទៅ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី១.០០០.០០០ រៀល ទៅ១០.០០០.០០០រៀល ឬត្រូវផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

៤.ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើតុលាការ អាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយឬច្រើន ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត១០.០០០.០០០រៀល ។ បណ្តឹងអាជ្ញា ដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគម ដែលតាំងឡើងតាមវិធានដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៥. ក្នុងករណីណាក៏ដោយ និយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ឬច្រើននាក់ ។

**មាត្រា ៦៧ ៈទោសប្រហារជីវិត**

ទោសប្រហារជីវិតត្រូវបានលុបចោលនៅប្រទេសកម្ពុជា ។

## ឃ. វិធានការសំរាប់ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់អំពើហិង្សា

ដូចយើងបានឃើញខាងលើមកហើយថា អំពើហិង្សាក្នុងគ្រួសារបានបន្សល់ទុកនូវផលវិបាកច្រើនលើសលប់ដល់គ្រួសារ និងសង្គម ។ ដូច្នេះដើម្បីទប់ស្កាត់ និងកាត់បន្ថយអំពើនេះ យើងគ្រប់ៗគ្នាគួររួមគ្នារកវិធីដោះស្រាយ ។

**១- មុនពេលហិង្សាកើតឡើង**

- ចេះអត់ធ្មត់ ដើម្បីដោះស្រាយបញ្ហា ដោយសន្តិវិធី តាមគ្រប់មធ្យោបាយ ដែលខ្លួនបានជួបប្រទះក្នុងគ្រួសាររបស់ខ្លួន ព្រោះបញ្ហាដែលកើតមានក្នុងគ្រួសារនីមួយៗ មិនដូចគ្នាទេ ។
- ចេះគិតទុកជាមុន ដើម្បីរកវិធានការទប់ទល់នូវរឿងដែលវានឹងកើតឡើង នៅថ្ងៃណាមួយ ក្នុងគ្រួសាររបស់យើង ( បើមានរឿងកើតឡើងរបៀបនេះ តើយើងត្រូវធ្វើដូចម្តេច ដើម្បីបញ្ចៀសអំពើហិង្សា ) ។
- ខិតខំឈ្វេងយល់គ្នាទៅវិញទៅមក ចំពោះសមាជិកក្នុងគ្រួសារ

- កុំប្រើហិង្សាដូចជា ជេរ រអ៊ូ បោកប្រាស់វត្ថុក្នុងផ្ទះ ងង៉ក់ និងបញ្ចេញទឹកមុខមិនសមរម្យ នៅពេលសមាជិកណាម្នាក់មានអារម្មណ៍មិនល្អ មកពីការនឿយហត់ជាពិសេសកំពុងស្រវឹងស្រា ។

**២- ការស្វែងរកមធ្យោបាយទប់ស្កាត់ អំពើហិង្សាដែលកំពុងកើតមាន**

- ដោះស្រាយជាបន្ទាន់មិនត្រូវអត់ទ្រាំហួសព្រំដែន ដោយមិនហ៊ានឱ្យអ្នកក្រៅដឹងមិនមែនជាមធ្យោបាយល្អទេ ជួនកាលវារិតតែធ្ងន់ធ្ងរថែមទៀត ឬរហូតដល់បាត់បង់អាយុជីវិតក៏មានដែរ ។
- រកទីកន្លែងសមស្របស្នាក់នៅបណ្តោះអាសន្នមួយរយៈ ដូចជា ផ្ទះឪពុក ម្តាយ អ្នកស្និទ្ធស្នាល ជាពិសេសអង្គការដែលទទួលបន្ទុកកម្មវិធីអំពើហិង្សាក្នុងគ្រួសារ ដើម្បីប្រឹក្សាយោបល់រកដំណោះស្រាយសមស្រប ។
- ផ្តល់ពត៌មានដល់រដ្ឋអំណាចមូលដ្ឋាន អង្គការស្ត្រីជាច្រើនទៀត ដែលមានកម្មវិធីនេះ និងតុលាការឱ្យជួយធ្វើអន្តរាគមន៍ក្នុងករណីណាដែលយល់ថា មិនអាចមានលទ្ធភាពដោះស្រាយខ្លួនឯងបាន ។

**៣- ការសំរុះសំរួលក្រោយពេលហិង្សា:**

ជំលោះក្នុងគ្រួសារ ជាពិសេសរវាងប្តី ប្រពន្ធ ត្រូវដោះស្រាយនៅក្នុងផ្ទៃក្នុងគ្រួសារសិន ។ ប្តី ប្រពន្ធគួររកវិធីដោះស្រាយបញ្ហា មិនត្រូវប្រើហិង្សាដែលគ្មានការពិចារណា វានឹងបង្កឱ្យមានមហន្តរាយក្នុងគ្រួសារ គួរកាត់បន្ថយឥទ្ធិពលពីសំណាក់សាច់ញាតិ មិត្តភក្តិ និងឪពុក ម្តាយ ដោយបែកផ្ទះដោយឡែក ទើបអាចជៀសវាងបញ្ហាហិង្សាក្នុងគ្រួសារបាន ។ ក្នុងពេលកំពុងមានហិង្សាកើតឡើង ដើម្បីការពារសុវត្ថិភាព ស្ត្រីគួរទៅស្នាក់នៅផ្ទះរបស់ម្តាយ ឬឪពុក ឬក្រុមញាតិសន្តានរបស់ខ្លួនសិន ឬជំរកបណ្តោះអាសន្នរបស់អង្គការ-សមាគម ដែលមានកម្មវិធីជួយជនរងគ្រោះដោយសារហិង្សាក្នុងគ្រួសារ និងស្វែងរកការជួយសំរបសំរួលពីសំណាក់អង្គការនានា ដែលធ្វើការជាមួយស្ត្រី ដូចជា *សមាគមអាដហុក អង្គការខេមរា អង្គការលីកាដូ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ សមាគមអភិវឌ្ឍន៍ស្ត្រីនៅកម្ពុជា អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី* ។ល។

# លទ្ធិប្រជាធិបតេយ្យ

**វត្ថុបំណង**

ក្រោយពីអ្នកអានបានអានចប់មេរៀននេះទៅ គេនឹងអាចវិភាគ និងបានយល់ថា :

១- របបគ្រប់គ្រងដែលមានលក្ខណៈបែបលទ្ធិប្រជាធិបតេយ្យ នឹងចាកផុតពីការធ្វើសង្គ្រាម និងផ្ទេរអំណាចដោយសន្តិវិធី ។

២- អំពីដំណើរការនៃការបោះឆ្នោតប្រកបដោយលទ្ធិប្រជាធិបតេយ្យ ។

## សេចក្តីផ្តើម

ការផ្តល់នូវនិយមន័យនៃពាក្យប្រជាធិបតេយ្យនេះ មានច្រើនបែបណាស់ទៅតាមអ្នកប្រើ ឬអ្នកបកស្រាយពាក្យនេះ ។ អ្វីដែលជាគោលទស្សនៈធំនៃពាក្យលទ្ធិប្រជាធិបតេយ្យគឺសំដៅអំណាច ហើយអំណាចនោះជារបស់ប្រជារាស្ត្រ ចេញពីប្រជារាស្ត្រ និង ដើម្បីប្រជារាស្ត្រ ។ នេះបញ្ជាក់អោយឃើញថាប្រជារាស្ត្របានផ្ទេរអំណាចរបស់ខ្លួន ទៅអោយអ្នកតំណាង ដើម្បីបំរើផលប្រយោជន៍អោយពួកគាត់ ។ មិនមែនផ្ទេរអំណាចទៅអោយអ្នកនយោបាយ ដើម្បីស្វែងរកលាភសក្ការៈសំរាប់បំរើបុគ្គលនិងគណបក្សខ្លួននោះទេ ។



**លទ្ធិ :** ការយល់ឃើញ ការនិយម សេចក្តីប្រកាន់ជឿ ជំនឿ

**ប្រជា :** ប្រជាជន ប្រជាពលរដ្ឋ ប្រជាករ ពពួកសត្វ ពពួកជន

**អធិបតេយ្យ** មកពីពាក្យ **អធិបតី** : ជាធំ

- លទ្ធិប្រជាធិបតេយ្យ គឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋដោយប្រជាពលរដ្ឋ
- លទ្ធិប្រជាធិបតេយ្យគឺជាឧបករណ៍សំរាប់អោយប្រជាពលរដ្ឋជ្រើសរើសអ្នកតំណាងរបស់ខ្លួន
- លទ្ធិប្រជាធិបតេយ្យ គឺជាការប្រគល់អំណាចជាធំដល់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួន ។
- លទ្ធិប្រជាធិបតេយ្យគឺជាការយកប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច ម្ចាស់វាសនារបស់ខ្លួន និងប្រទេសជាតិ ។

ជាក់ស្តែងមានរបបគ្រប់គ្រងនយោបាយប្លែកៗគ្នាជាច្រើន ដែលបានអះអាងថាជារបបលទ្ធិប្រជាធិបតេយ្យដែរ ។ ដើម្បីឱ្យងាយយល់ថារបបបែបណា ដែលមានលក្ខណៈលទ្ធិប្រជាធិបតេយ្យនោះ គេបានសន្មត់ថា ទាល់តែរបបនយោបាយនោះ មានធាតុផ្សំសំខាន់ធំៗបី និងមានដំណើរការដូចខាងក្រោមនេះ :

## ១. ស្ថាប័ននៃរបបប្រជាធិបតេយ្យ

- ស្ថាប័នសភា និងព្រឹទ្ធសភា (អំណាចនីតិបញ្ញត្តិ)
- ស្ថាប័នរដ្ឋាភិបាល (អំណាចនីតិប្រតិបត្តិ)
- សាលាជំរះក្តី (អំណាចតុលាការ )

ស្ថាប័នទាំងបីខាងលើនេះ ត្រូវមានការបែងចែកអំណាចគ្នាឱ្យបានច្បាស់លាស់ ហើយមិនអាចស្ថាប័នណាមួយ ប្រើអំណាចគ្របដណ្តប់លើស្ថាប័នមួយទៀតបានទេ តែត្រូវមានកិច្ចសហការគ្នា ។ ឧទាហរណ៍ : អំណាចរដ្ឋាភិបាលមិនអាចបញ្ជាអំណាចតុលាការ ឃាត់ខ្លួន ឬវិនិច្ឆ័យទោសដល់ជនណាមួយបានទេ ។ រដ្ឋាភិបាលគ្រាន់តែសហការជាមួយតុលាការ ដោយបង្កលក្ខណៈងាយស្រួលដល់ការងារតុលាការ ដូចជា មិនលាក់បាំង ឬការពារជនសង្ស័យ ឧក្រិដ្ឋជន ដើម្បីឱ្យតុលាការចាត់ការតាមនីតិវិធី ។

ក្រៅពីស្ថាប័នទាំងបីខាងលើនេះនៅមាន "*ស្ថាប័នត្រួតពិនិត្យ*" មួយចំនួនទៀត ដែលមានសារៈសំខាន់ក្នុងរបបលទ្ធិប្រជាធិបតេយ្យ មានដូចតទៅ :

- គណៈកម្មាធិការជាតិប្រឆាំងនឹងអំពើពុករលួយ
- គណៈកម្មាធិការជាតិសិទ្ធិមនុស្ស

- ក្រុមប្រឹក្សាសវនកម្ម
- អាំបុតសមិន ជាអង្គការសង្គមមួយឯករាជ្យ របស់រដ្ឋ សំរាប់ដោះស្រាយលើវិវាទ របស់មន្ត្រីដែលអនុវត្ត ខុសនីតិវិធី (បញ្ហាសង្គមកិច្ច បញ្ហារដ្ឋបាលជាដើម) ។

## ២. នីតិវិធីនៃលទ្ធិប្រជាធិបតេយ្យ

នីតិវិធីនៃលទ្ធិប្រជាធិបតេយ្យនេះគឺសំដៅពិចារណា និងសង្កត់ទៅលើអភិក្រមលទ្ធិប្រជាធិបតេយ្យ ដែល តំរូវអោយមានលក្ខខណ្ឌគន្លឹះខាងក្រោម :

- **ការបោះឆ្នោត**

យន្តការនៃការផ្លាស់ប្តូរអ្នកដឹកនាំ និងការជ្រើសរើសអ្នកតំណាង តាមវិធានការនៃរបបប្រជាធិបតេយ្យ គឺប្រព្រឹត្តិទៅតាមរយៈការបោះឆ្នោតដោយទៀងទាត់ និងមានលក្ខណៈសេរី និងយុត្តិធម៌ ។ យ៉ាងហោចណាស់ គោលការណ៍ជាវិជ្ជមាននេះត្រូវបានយកមកអនុវត្ត :

+ មានលក្ខណៈសកល ដោយផ្ទាល់ និងសម្ងាត់
+ មិនមានអំពើហិង្សា ដូចជាការសម្លាប់ ឬការគំរាមកំហែងនយោបាយ
+ មិនមានការកេងបន្លំសន្លឹកឆ្នោត
+ គណបក្ស ឬបេក្ខជនចូលរួមប្រកួតត្រូវតែមានសេរីភាពស្មើគ្នាក្នុងការងារធ្វើសកម្មភាពរកសន្លឹកឆ្នោត ដោយអនុលោមទៅតាមច្បាប់បោះឆ្នោត ។
+ គណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវតែបំពេញការងារ ដោយ ឯករាជ្យ និងអព្យាក្រឹតមិនលំអៀង ។
+ រដ្ឋអំណាច នគរបាល យោធា តុលាការ កងរាជអាវុធហត្ថ ត្រូវតែប្រកាន់ជំហរអព្យាក្រឹត នៅក្នុងដំណើរការបោះឆ្នោតនេះ ។

- **ការតាក់តែង និងអនុម័តច្បាប់**

ដំណើរការធ្វើសេចក្តីព្រាងច្បាប់ និងអនុម័តច្បាប់ត្រូវតែឱ្យមានការជជែកពិភាក្សាដេញដោលគ្នាទាំងនៅក្នុងសភា និងក្រៅសភា មានន័យថា ឱ្យមានការចូលរួមមានមតិយោបល់ពីសាធារណជន និងសង្គមស៊ីវិល លើការតាក់តែងច្បាប់ និងអនុម័តច្បាប់ ។

- **ការធ្វើសេចក្ដីសំរេចនានា**

ការសំរេចចិត្តជាកត្តាមួយសំខាន់ណាស់ពីព្រោះការសំរេចនេះ អាចមានផលអាក្រក់ផង និងផលល្អផង។ អាស្រ័យ ហេតុនេះហើយ ការសំរេចចិត្តរបស់រាជរដ្ឋាភិបាលត្រូវតែមានលក្ខណៈចំហ និងតម្លាភាព ។ ឧទាហរណ៍:

+ ក្នុងក្របខ័ណ្ឌឃុំ-សង្កាត់ រាល់ការសំរេចចិត្ត ឬការគ្រប់គ្រងក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែឱ្យប្រជារាស្ត្រក្នុងឃុំ បានដឹងឮទាំងអស់គ្នា និងមានតម្លាភាព ។
+ នៅក្នុងក្របខ័ណ្ឌឃុំ-សង្កាត់ រាល់ការសំរេចចេញដីកា ឬគំរោងការអភិវឌ្ឍន៍នានារបស់ឃុំ-សង្កាត់ ត្រូវតែឱ្យមានការចូលរួមមានមតិយោបល់ពីអង្គការសង្គម ក៏ដូចពីសំណាក់ប្រជារាស្ត្រ ។

- **ការដោះស្រាយទំនាស់**

យន្តការដោះស្រាយទំនាស់ ត្រូវតែឱ្យមានលក្ខណៈច្បាស់លាស់ និងស្អាតស្អំ ដោយអ្នកដោះស្រាយនោះត្រូវឈរ លើទស្សនៈឥតលំអៀង និងអនុវត្តតាមច្បាប់ដែលមានចែង ។ ឧទាហរណ៍: ឃុំ-សង្កាត់ ត្រូវចេះរៀបចំនិងចាត់វិធានការដោះស្រាយនូវទំនាស់ដែលកើតមាននៅក្នុងឃុំ-សង្កាត់របស់ខ្លួន ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ហើយត្រូវអនុលោមទៅតាមច្បាប់ជាធរមាន ។

## ៣. តម្លៃនៃលទ្ធិប្រជាធិបតេយ្យ

- **សេរីភាពក្នុងការបញ្ចេញមតិ:** សេរីភាពខាងសារពត៌មាន គឺជាតម្លៃ ខ្ពស់បំផុតមួយនៃលទ្ធិប្រជាធិបតេយ្យ ។ ព្រោះថាបើគ្មានសេរីភាពបញ្ចេញមតិនេះទេ គឺពុំមានការរិះគន់ ឬឱ្យយោបល់ទៅអ្នកដឹកនាំឡើយ ។ បើមានតែមតិ យោបល់របស់អ្នកដឹកនាំ ឬក្រុមអ្នកដឹកនាំមួយចំនួនតូច ដែលយកមកដឹកនាំគ្រប់គ្រងសង្គម ហើយពុំមានការផ្ដល់មតិទិតៀនកែលំអពីអ្នកផ្សេងទៀតទេនោះ នាំឱ្យមានការខុសឆ្គង ដូចសម័យខ្មែរក្រហមជាក់ជាមិនខានឡើយ ។
- **ការរើសអើងដល់អប្បភាគជន** (ក្រុមជនភាគតិច): មានដូចជាក្រុមជនជាតិភាគតិច ក្រុមនយោបាយប្រឆាំងក្រុមនិយមសាសនាផ្សេងៗ ។ល។ ការរើសអើងដល់ក្រុមជនភាគតិចនេះ ពីសំណាក់ក្រុមអ្នកភាគច្រើន ដែលជាក្រុមកាន់អំណាចរដ្ឋនេះ នឹងបណ្ដាលឱ្យមានអំពើហិង្សា និងអស្ថិរភាពកើតឡើង

ជាក់ជាមិនខានឡើយ ។ ដូច្នេះទាល់តែមានការអនុគ្រោះ ទើបអាចរក្សាស្ថិរភាព និងពង្រឹងលទ្ធិប្រជាធិបតេយ្យ ។

- គោលការណ៍លទ្ធិប្រជាធិបតេយ្យ : មិនមែនមានន័យថាក្រុមអ្នកភាគច្រើនបានទទួលសម្លេងឆ្នោតឈ្នះលើក្រុមអ្នកភាគតិចដទៃទៀត ហើយមកគ្រប់គ្រងប្រទេស ឬឃុំ-សង្កាត់ ដោយគ្រាន់តែបំរើក្រុមអ្នកគាំទ្ររបស់ខ្លួន ហើយធ្វើបាប ឬកៀបសង្កត់ដល់ក្រុមភាគតិចនោះទេ ។ ការគ្រប់គ្រងដឹកនាំគឺធ្វើទៅលើប្រជារាស្ត្រទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយជនជាតិ សាសនា ឋានៈសង្គម ភេទនោះឡើយ ។

អ្នកដឹកនាំដែលគ្រប់គ្រងមានការរើសអើង គឺពុំមែនជាអ្នកកាន់លទ្ធិប្រជាធិបតេយ្យទេ ។

- សិទ្ធិរបស់បុគ្គល ឬសិទ្ធិមនុស្ស : គឺគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ។ មិនការគោរពសិទ្ធិមនុស្ស ក៏ពុំមានលទ្ធិប្រជាធិបតេយ្យដែរ ។

- ការទទួលខុសត្រូវរបស់អ្នកដឹកនាំ : អ្នកដឹកនាំត្រូវមានស្មារតីទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន ដូចជាមិនពុករលួយ មិនប្រកាន់បក្សពួក (និន្នាការនយោបាយ) គ្រួសារនិយម មិនផ្តាច់ការ ។

ប្រការដែលប្រជារាស្ត្របោះឆ្នោតឱ្យទៅកាន់អំណាចថ្នាក់ជាតិ ឬអំណាចឃុំ-សង្កាត់នោះ គឺប្រជារាស្ត្រប្រគល់អំណាចជូន ដើម្បីដឹកនាំគ្រប់គ្រងប្រទេស ឬឃុំ-សង្កាត់ឱ្យបានរីកចំរើន សំរាប់ជាគុណប្រយោជន៍ដល់ប្រជារាស្ត្រទូទៅ ។ការរៀបរាប់លំអិតអំពីតួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់នៅក្នុងមេរៀនស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។

# វិមជ្ឈការ និង
# វិសហមជ្ឈការនៅកម្ពុជា

**វត្ថុបំណង**

ក្រោយពីអ្នកអានបានអានចប់មេរៀននេះ គេនឹងយល់ថា :

១- ជាយន្តការថ្មីមួយ ដើម្បីកាត់បន្ថយអំណាចមជ្ឈការ និងឈានទៅដល់ការស្វ័យសំរេចនៃគំរោងអភិវឌ្ឍន៍ភូមិ ឃុំ-សង្កាត់របស់គេ ។

២- ការអភិវឌ្ឍន៍ឃុំ-សង្កាត់នៅក្នុងមូលដ្ឋាន ត្រូវតែមានការចូលរួមនិងសំរេច ពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងស្ថាប័នរដ្ឋ ។

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈមួយ តាំងពីខែមករា ឆ្នាំ១៩៩៩មកម្ល៉េះ ដើម្បីធ្វើឱ្យរដ្ឋបាលរបស់ខ្លួនមានអព្យាក្រឹតភាព សមត្ថភាព ប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ ។ កម្មវិធីកំណែទម្រង់នេះមានវិធីពីរយ៉ាងដើម្បីធ្វើ ទំនើបនីយកម្មរដ្ឋបាលប្រយោជន៍ឈានទៅរកការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ (គឺការរៀបចំក្រុមប្រឹក្សាឃុំ-សង្កាត់ និងការពង្រឹងរដ្ឋបាលដែនដីរបស់រដ្ឋ ពោលគឺរដ្ឋបាលខេត្ត និងរដ្ឋបាលស្រុក) ។

### តើវិមជ្ឈការ និង វិសហមជ្ឈការគឺជាអ្វី?

### ១. និយមន័យ

ការរៀបចំឃុំ-សង្កាត់ ដែលត្រូវបោះឆ្នោតជ្រើសរើស មេឃុំឬចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ-សង្កាត់ដោយប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់ គឺជាបន្ទាត់នយោបាយថ្មីមួយដើម្បីគ្រប់គ្រងនិងអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់ ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ទទួលបន្ទុកអនុវត្តភារកិច្ចដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់។ ឃុំសង្កាត់ក៏ត្រូវមានមធ្យោបាយមួយចំនួន ដូចជាធនធានហិរញ្ញវត្ថុផ្ទាល់ខ្លួន ដើម្បីសំរេចកម្មវិធី

សកម្មភាពរបស់ខ្លួន ។

- *<u>វិមជ្ឈការ</u>* *ជាការផ្ទេរ សិទ្ធិអំណាច ការទទួលខុសត្រូវ និង ធនធានមួយចំនួន ពីរដ្ឋាភិបាលថ្នាក់ជាតិ ទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋ តាមលក្ខណៈលទ្ធិប្រជាធិបតេយ្យ ។*



- *<u>វិសហមជ្ឈការ</u>* *គឺជាការពង្រឹងរដ្ឋបាលដែនដីរបស់រដ្ឋ ពោលគឺរដ្ឋបាលខេត្ត-ក្រុង និងរដ្ឋបាលស្រុក-ខណ្ឌ ដែលអភិបាលខេត្ត-ក្រុង និងអភិបាលស្រុក-ខណ្ឌ មន្ទីរខេត្ត-ក្រុង និងការិយាល័យស្រុក-ខណ្ឌ ត្រូវបានរដ្ឋាភិបាលប្រគល់សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសំរេចខ្លះៗ ជំនួសឱ្យរដ្ឋាភិបាល និងរដ្ឋបាលកណ្តាលនៃក្រសួងនានា ។*

## ២. តួនាទី និងមុខងារឃុំ-សង្កាត់

នៅពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេឃុំ-ចៅសង្កាត់ធ្វើសេចក្តីសំរេចគឺគេធ្វើក្នុងនាមប្រជាពលរដ្ឋ ដែលបានបោះឆ្នោតជ្រើសរើសពួកគេ ។ គេមានមធ្យោបាយផ្ទាល់ខ្លួន ជាពិសេសគឺធនធានហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលបានកំណត់នៅក្នុងថវិកា ។ ថវិកានេះគឺដាច់ស្រឡះទាំងស្រុងពីថវិការដ្ឋ ។ មេឃុំ-ចៅសង្កាត់ និង ក្រុមប្រឹក្សាឃុំ-សង្កាត់មានតួនាទី និងត្រូវទទួលខុសពីរ គឺ:

- ជាតំណាងចំពោះមុខប្រជាពលរដ្ឋដែលបោះឆ្នោត ជ្រើសរើសពួកគេ

- ជាភ្នាក់ងារតំណាងរដ្ឋ ស្របមាត្រា៤២-៤៣ និង៤៤នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ-សង្កាត់ ដែលអនុម័តដោយសភា ។តាមក្របខ័ណ្ឌនេះឃុំ-សង្កាត់ស្វ័យគ្រប់គ្រងដោយខ្លួនឯង ។

ឃុំ-សង្កាត់មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងនានា និងរដ្ឋបាលកណ្តាលទេ ។ ឃុំ-សង្កាត់ គឺជាមណ្ឌលការសំរេចចិត្ត និងជាមណ្ឌលនៃសិទ្ធិអំណាច តែយ៉ាងណាក៏ដោយ ក៏ឃុំ-សង្កាត់ស្ថិតនៅក្រៅពីអំណាចកណ្តាល មានន័យថា ឃុំ-សង្កាត់ត្រូវបានធ្វើវិមជ្ឈការ ដែលតួនាទី មុខងារ និងអំណាចរបស់គេ ត្រូវកំណត់លំអិតបន្ថែមទៀតដោយអនុក្រឹត្យ ស្នើដោយក្រសួងមហាផ្ទៃ (មាត្រាទី៤៧នៃច្បាប់គ្រប់គ្រងឃុំ-សង្កាត់) ។

ផ្ទុយទៅវិញនៅពេល ដែលអភិបាលខេត្ត-ក្រុង និងប្រធានមន្ទីរខេត្តធ្វើសេចក្តីសំរេចនានានោះបានន័យថា អភិបាលខេត្ត-ក្រុង និងប្រធានមន្ទីរខេត្ត-ក្រុងទាំងនោះ អនុវត្តក្នុងនាមរដ្ឋាភិបាល និងក្រសួងនានា ដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនោះ ។ គេប្រើប្រាស់មធ្យោបាយរបស់រដ្ឋ ជាពិសេសគឺមធ្យោបាយហិរញ្ញវត្ថុ ដូចមានគ្រោងនៅក្នុងថវិការដ្ឋ ដែលអនុម័តដោយសភា ។ សិទ្ធិអំណាចដែលអភិបាលខេត្ត-ក្រុង និងប្រធានមន្ទីរខេត្ត-ក្រុងអនុវត្ត និងឥណទានដែលគេគ្រប់គ្រង គឺក្រសួងនានាជាអ្នកប្រគល់ឱ្យ ។ គេត្រូវទទួលខុសត្រូវចំពោះសេចក្តីសំរេចដែលខ្លួន បានធ្វើនៅចំពោះមុខរដ្ឋាភិបាល ហើយបានធ្វើ "វិសហមជ្ឈការ" ពោលគឺរដ្ឋបាលមិនមែនស្ថិតនៅថ្នាក់កណ្តាលទេ ប៉ុន្តែគឺរដ្ឋបាលនេះធ្វើការជាមួយថ្នាក់កណ្តាល ។ ដូច្នេះរដ្ឋបាលនៅតែអនុវត្តការងារតាមបែបមជ្ឈការជុំវិញរដ្ឋាភិបាល ។

## ៣. សារៈប្រយោជន៍នៃវិមជ្ឈការ

ការបង្កើតឃុំ-សង្កាត់ *"វិមជ្ឈការ"* ស្វយ័តពីរដ្ឋ និងការពង្រឹងរដ្ឋបាល *"វិសហមជ្ឈការ"* នៃរដ្ឋមានផលចំណេញច្រើនដូចជាក្នុងការជំរុញអោយមានការចូលរួមជាសមាគមកាន់តែច្រើនឡើង ការពង្រឹងការទទួលខុសត្រូវនៃស្ថាប័នរដ្ឋាភិបាល ការបង្កើនទូវពត៌មានសំបូរបែប នៅក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋ និងរដ្ឋាភិបាល ការបង្កើនគំរោងអភិវឌ្ឍន៍អោយរឹតតែមាននិរន្តរភាព ពង្រឹងនូវតម្លាភាព ការជំរុញអោយមាននូវការទទួល ខុសត្រូវកាន់តែច្រើនឡើង សំរេចបាននូវការបន្តវេន ជាថ្មីខាងនយោបាយ និងពង្រឹងលទ្ធិប្រជាធិបតេយ្យថ្នាក់ជាតិ ។

# នីតិរដ្ឋ ឬ ធម្មាធិបតេយ្យ

**វត្ថុបំណង**

ក្រោយពីអ្នកអានបានអានចប់មេរៀននេះទៅ គេនឹងអាចវិភាគ និងបានយល់អំពី :

១- អត្ថន័យនៃពាក្យថា *នីតិរដ្ឋ ឬ ធម្មាធិបតេយ្យ*។

២- គោលការណ៍ នៃ*នីតិរដ្ឋ ឬ ធម្មាធិបតេយ្យ* ។

## សេចក្តីផ្តើម

ការលើកឡើងអំពីនីតិរដ្ឋ ឬធម្មាធិបតេយ្យ គឺស្របពេលដែលប្រទេសកម្ពុជាចាប់ផ្តើមប្រើប្រាស់ច្បាប់ក្នុងការគ្រប់គ្រងរដ្ឋ។ ដើម្បីឱ្យប្រទេសមួយក្លាយជានីតិរដ្ឋពិតប្រាកដលុះត្រាតែប្រទេសនោះ មានច្បាប់គ្រប់គ្រាន់ មានច្បាប់ដែលល្អ អនុលោមទៅតាមគោលការសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យ ហើយទាំងភ្នាក់ងារប្រតិបត្តិច្បាប់ ទាំងប្រជាពលរដ្ឋត្រូវតែអនុវត្តទៅតាមបទប្បញ្ញត្តិ និងនីតិវិធីដែលកំណត់ដោយច្បាប់ ។

### ១. នីតិរដ្ឋ / ធម្មាធិបតេយ្យ

**នីតិ**= ច្បាប់ /ធម្ម ( បា.)/ធម៌ ( សំ.)

ច្បាប់គឺជា បញ្ញត្តិទាំងឡាយដែលតាក់តែង និងអនុម័តដោយស្ថាប័ន ឬអង្គការចាត់តាំងនៃរដ្ឋ ។

**ក~ប្រភេទច្បាប់:**

*-ច្បាប់ជាតិ /ច្បាប់ក្នុងប្រទេស*

- នីតិសាធារណៈ ( នីតិរដ្ឋធម្មនុញ្ញ,នីតិរដ្ឋបាល,នីតិហិរញ្ញវត្ថុ,នីតិព្រហ្មទណ្ឌ)
- នីតិឯកជន ( នីតិពាណិជ្ជកម្ម,នីតិការងារ,នីតិធានារ៉ាប់រង,នីតិដឹកជញ្ជូន ។ល ។)

*-ច្បាប់អន្តរជាតិ*

- នីតិសាធារណៈអន្តរជាតិ ( សំរាប់ទំនាក់ទំនងរវាងប្រទេស និង ប្រទេស)
- នីតិឯកជនអន្តរជាតិ ( សំរាប់គ្រប់គ្រងការទំនាក់ទំនងរវាងឯកជន ដែលមានជនជាតិបរទេស និងជនជាតិនៃប្រទេស)

ខ. មុខងារនៃច្បាប់:

- ថែរក្សារបៀបរៀបរយសង្គម
- ដោះស្រាយជម្លោះ ឬវិវាទ ដែលកើតឡើងពីការរំលោភផ្សេងៗ
- ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ
- ថែរក្សាប្រពៃណីទំនៀមទំលាប់ល្អនៃសង្គម
- ថែរក្សាយុត្តិធម៌សង្គម

រដ្ឋ

ធាតុផ្សំនៃរដ្ឋរួមមាន:

- ប្រជាពលរដ្ឋ
- ទឹកដី
- រដ្ឋអំណាច ឬរដ្ឋាភិបាល
- អត្តសញ្ញាណជាតិ ( វប្បធម៌ ប្រពៃណី អក្សរសាស្ត្រ សិល្បៈ ។ល។)

☞ **នីតិរដ្ឋ ធម្មាធិបតេយ្យ:** គឺសំដៅទៅលើ *"របបដឹកនាំរដ្ឋ ឬប្រទេសដែលយកច្បាប់ជាធំ ឬអាស្រ័យ ដោយច្បាប់"* ។

ក្នុងន័យនេះ នីតិរដ្ឋ គឺជារដ្ឋមួយដែលគ្រប់គ្រងដោយច្បាប់ មិនមែនគ្រប់គ្រងដោយបុគ្គលណាម្នាក់ ឬក្រុមណាមួយឡើយ។ ពេលដែលច្បាប់ត្រូវបានគេតាក់តែង អនុម័ត និងចូលជាធរមានរួចហើយនោះ គ្មានបុគ្គលណា ឬក្រុមណាអាចនៅពីលើច្បាប់ ឬបំពានច្បាប់តាមអំពើចិត្តឡើយ បើពុំនោះទេវានឹងក្លាយជានីតិរដ្ឋតែសំបកក្រៅប៉ុណ្ណោះ។

យោងតាមមាត្រា ៤៩ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។ ដូច្នេះ ប្រជាពលរដ្ឋទូទៅក៏ដូចជាមន្ត្រីរាជការចាប់ពីថ្នាក់លើដល់ថ្នាក់ក្រោមត្រូវគោរពច្បាប់ និងមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋពិតប្រាកដនោះ។ បុគ្គលណាមួយដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ត្រូវតែមានទោសទៅតាមអភិក្រមនៃច្បាប់ដែលមាន។

គួរកត់សំគាល់ថា ច្បាប់ដែលល្អសំរាប់យកទៅអនុវត្តក្នុងនីតិរដ្ឋនោះ គឺជាច្បាប់ដែលអនុលោមទៅតាមគោលការណ៍ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ។ ចំពោះរដ្ឋដែលប្រើច្បាប់ ឬអំណាចផ្តាច់ការ មិនអាចហៅថានីតិរដ្ឋបានទេ។

## ២. ហេតុអ្វីចាំបាច់មាននីតិរដ្ឋ?

- ធានានូវការគោរពសិទ្ធិមនុស្ស និងការអនុវត្តលទ្ធិប្រជាធិបតេយ្យ

- ធានានូវការបែងចែកអំណាចទៅតាមនីតិវិធីនៃច្បាប់
- ទប់ស្កាត់ការប្រើអំណាចផ្តាច់ការ
- ធានានិរន្តរភាពនៃផែនការសកម្មភាពរបស់បុគ្គល ឬក្រុមណាមួយ (វិនិយោគ ពាណិជ្ជកម្ម...)
- ការពារសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋ

## ៣. គោលការណ៍សំខាន់ៗដែលកំណត់នីតិរដ្ឋ

### ក. រដ្ឋធម្មនុញ្ញជាច្បាប់កំពូល

ច្បាប់ទាំងឡាយត្រូវអនុលោមទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលបញ្ជាក់ពីទម្រង់របស់រដ្ឋ និង ការបែងចែកអំណាចរដ្ឋ។

### ខ. យន្តការដោះស្រាយទំនាស់ ឬវិវាទ

- យន្តការដោះស្រាយទំនាស់បែបរដ្ឋបាល (ឧ. គណៈកម្មការសុរិយោដី)
- យន្តការដោះស្រាយទំនាស់បែបតុលាការ (ឧ. សាលាដំបូង សាលាឧទ្ធរណ៍ តុលាការកំពូល)
- យន្តការដោះស្រាយទំនាស់បែបអង្គការនីតិបញ្ញត្តិ (ឧ. គណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងរបស់រដ្ឋសភា)

### គ. ឯករាជ្យភាពនៃប្រព័ន្ធតុលាការ

- ចៅក្រមត្រូវមានសមត្ថភាព មានឯករាជ្យភាព និងបទពិសោធន៍
- ព្រះរាជអាជ្ញា ត្រូវជាអ្នកដើមចោទនូវរាល់បទអាជ្ញាទាំងអស់
- ត្រូវមានមេធាវីការពារក្តី
- សវនាការត្រូវមានលក្ខណៈសាធារណៈ និងគោរពតាមនីតិវិធីត្រឹមត្រូវ

### ឃ. តម្រូវការច្បាប់ និងការអនុវត្តច្បាប់

ប្រទេសដែលជានីតិរដ្ឋត្រូវមានច្បាប់គ្រប់គ្រាន់ ច្បាប់ដែលអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ហើយផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងសង្គម។ ការតាក់តែងច្បាប់ ត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ពីអង្គការសង្គមស៊ីវិល និងសាធារណៈជនឱ្យបានទូលំទូលាយ ។ គ្មានបុគ្គលអាចនៅពីលើច្បាប់បានឡើយ ទោះមានឋានៈអ្វីក៏ដោយ ។